អង្គការសមាគមធាងត្នោត
Sahmakum Teang Tnaut Organization · a Cambodian Urban NGO

ការពិត និងតួលេខ #៥៣

# ការទទួលបានសេវាសាធារណៈ និង ផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ

## ការវិភាគតំបន់តាំងទីលំនៅថ្មីចំនួនប្រាំមួយក្នុងទីក្រុងភ្នំពេញ និងខេត្តកណ្ដាល

ខែមេសា ឆ្នាំ២០២៥



# សេចក្តីសង្ខេប



*រូបភាពទី១៖ ស្ថានភាពលំនៅឋាន និងប្រជាពលរដ្ឋនៅភូមិវិហារសួគ៌ជើង ឆ្នាំ២០២៥*

ប្រទេសកម្ពុជាកំពុងប្រឈមនឹងបញ្ហាជាច្រើនដែលបណ្តាលមកពីកំណើននគរូបនីយកម្មយ៉ាងឆាប់រហ័ស កំណើនប្រជាជន និងភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ។ កត្តាទាំងនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការផ្តល់សេវាសាធារណៈ ជាពិសេសសម្រាប់ទីតាំងលំនៅឋានក្រីក្រ ដែលត្រូវបានផ្លាស់ទីលំនៅដោយសារគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ការសិក្សាស្រាវជ្រាវនេះ ពិនិត្យស្ថានភាពបច្ចុប្បន្ននៃការទទួលបានសេវាសាធារណៈ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុរបស់ទីតាំងលំនៅឋានក្រីក្រចំនួនប្រាំមួយក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដែលបានផ្លាស់ទីលំនៅចន្លោះឆ្នាំ២០២០ ដល់ឆ្នាំ២០២៣។ ទីតាំងសិក្សាទាំងនេះស្ថិតក្នុងខណ្ឌព្រែកព្នៅ ខណ្ឌឫស្សីកែវ និងខណ្ឌច្បារអំពៅនៃរាជធានីភ្នំពេញ និងស្រុកខ្សាច់កណ្តាលនៃខេត្តកណ្តាល។ ការសិក្សាបានផ្តោតលើគោលបំណងសំខាន់ចំនួនបី៖ទីមួយ ការវាយតម្លៃការផ្តល់សេវាសាធារណៈជាមូលដ្ឋានសំខាន់ៗទៅដល់អ្នកដែលត្រូវបានផ្លាស់ទីតាំងលំនៅឋានថ្មី។ ទីពីរ ការពិនិត្យមើលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងសមត្ថភាពបន្សាំខ្លួនរបស់ប្រជាពលរដ្ឋនៅទីតាំងលំនៅឋានថ្មី។ ទីបី ការលើកឡើងជាអនុសាសន៍ដែលអាចអនុវត្តបានសម្រាប់ភាគីពាក់ព័ន្ធ។

ដើម្បីសម្រេចបាននូវគោលបំណងទាំងនេះ វិធីសាស្ត្រចម្រុះត្រូវបានប្រើប្រាស់នៅក្នុងកិច្ចការស្រាវជ្រាវ ដោយរួមបញ្ចូលទាំងវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណ និងបែបគុណភាព ដែលរួមបញ្ចូលទាំងការចុះពិនិត្យនៅទីតាំងផ្ទាល់ កិច្ចពិភាក្សាជាក្រុម និងការសម្ភាសបែបស៊ីជម្រៅជាមួយអ្នកដែលត្រូវបានផ្លាស់ទីតាំងលំនៅឋានថ្មី និងតំណាង

សង្គមស៊ីវិល។ ការពិនិត្យ និងវិភាគទៅលើគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ត្រូវបានធ្វើឡើង ដើម្បីផ្តល់នូវការយល់ដឹងឱ្យកាន់តែទូលំទូលាយ។ ទិន្នន័យត្រូវបានប្រមូលពីប្រភពជាច្រើន ដើម្បីធានាបាននូវទិន្នន័យគ្រប់ជ្រុងជ្រោយ និងជួយដល់ការវាយតម្លៃរួមអំពីបញ្ហាប្រឈម និងដំណោះស្រាយទាក់ទងនឹងការកែលម្អការផ្តល់សេវាសាធារណៈ និងភាពធន់នឹងអាកាសធាតុសម្រាប់សហគមន៍ដែលងាយរងគ្រោះ។

ការសិក្សានេះបានរកឃើញលទ្ធផលសំខាន់ៗមួយចំនួន រួមមាន ការផ្តល់សេវាសាធារណៈជាមូលដ្ឋានមិនបានពេញលេញដូចជា ទឹកស្អាត អគ្គិសនី សេវាថែទាំសុខភាព និងការអប់រំជាដើម។ លើសពីនេះទៀត កង្វះហេដ្ឋារចនាសម្ព័ន្ធ ដែលរៀបចំមិនបានល្អ ឬមិនគ្រប់គ្រាន់ បណ្តាលឱ្យពួកគេរស់នៅក្នុងលក្ខខណ្ឌមិនទាន់ល្អប្រសើរនៅឡើយ។ ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចបានក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរបន្ថែមទៀតសម្រាប់ពួកគេ ដោយទីតាំងឆ្ងាយពីទីក្រុងជាឧបសគ្គដល់ស្ថិរភាពការងារ ដែលនាំឱ្យជីវភាពរស់នៅរបស់ពួកគេនៅតែមានកម្រិតទាប។ ការណ៍នេះ បានបង្កើនជាភាពងាយរងគ្រោះបន្ថែមទៀតពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុដល់ពួកគេ។ លើសពីនេះទៀត ទីតាំងដែលផ្លាស់ទីលំនៅជារឿយៗប្រឈមនឹងបញ្ហាដូចជា ទឹកកខ្វក់ ការកើនកម្តៅលំនៅឋានមិនទាន់សមរម្យ និងកង្វះហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ។ ជាងនេះទៅទៀត ពួកគេក៏មានការយល់ដឹងតិចតួចអំពីវិធីសាស្ត្របន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុផងដែរ។ បញ្ហាទំនាក់ទំនង និងប្រព័ន្ធគាំពារសង្គមក៏លេចចេញជាបញ្ហាប្រឈមចម្បងផងដែរ ដោយបន្ទាប់ពីផ្លាស់ទីលំនៅថ្មីបានធ្វើឱ្យពួកគេមានភាពតានតឹងផ្លូវចិត្ត ចំណែកទំនាក់ទំនងសង្គម និងភាពស្អិតរមួតរបស់ពួកគេក៏បានធ្លាក់ចុះ និងគ្រួសារមួយចំនួនបានបាត់បង់ប្រព័ន្ធគាំពារសង្គម ដោយសារប័ណ្ណសមធម៌ផុតសុពលភាព និងមិនអាចបន្តដើម្បីប្រើប្រាស់បាននៅទីតាំងថ្មី។ ជាចុងក្រោយ ទោះបីជាកម្ពុជាមានគោលនយោបាយទាក់ទងនឹងដំណោះស្រាយការផ្លាស់ទីតាំងលំនៅឋានថ្មី និងការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុក៏ដោយ ក៏ការអនុវត្តនៅមិនទាន់បានគ្រប់ជ្រុងជ្រោយ នៅឡើយ។ កត្តាទាំងនេះ អាចបណ្តាលមកពី ធនធាននៅមានកម្រិត ការសម្របសម្រួលអន្តរស្ថាប័នមិនទាន់បានល្អ និងយន្តការត្រួតពិនិត្យមិនទាន់គ្រប់ជ្រុងជ្រោយ។

ផ្អែកលើការស្រាវជ្រាវសំខាន់ៗ អនុសាសន៍ជាច្រើនត្រូវបានស្នើឡើង ដើម្បីដោះស្រាយបញ្ហាប្រឈមរបស់អ្នកដែលបានផ្លាស់ទីលំនៅថ្មី ដែលអនុសាសន៍ទាំងនេះរួមមាន៖

- ដើម្បីកែលម្អការផ្តល់សេវាសាធារណៈរួមមាន ការផ្គត់ផ្គង់ទឹកស្អាត អនាម័យ អគ្គិសនី សេវាថែទាំសុខភាព និងការអប់រំ អាជ្ញាធរមូលដ្ឋានគួរតែបង្កើតក្រុមការងារជំនាញដោះស្រាយបញ្ហាទាក់ទងនឹងការតាំងទីលំនៅថ្មី ដើម្បីធានាឱ្យបាននូវដំណោះស្រាយទាន់ពេលវេលា ម៉្យាងវិញទៀតសេវាសធារណៈជាមូលដ្ឋានទាំងនេះ គួរត្រូវបានរៀបចំឱ្យបានរួចរាល់មុនពួកគេទៅដល់ទីតាំងថ្មី។ លើសពីនេះទៀតអាជ្ញាធរមូលដ្ឋានគួរពិនិត្យមើលលទ្ធភាពក្នុងការស្វែងរកដៃគូរអភិវឌ្ឍន៍ដែលអាចផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនឱកាសការងារ។
- ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងអាទិភាពសំខាន់ៗផ្សេងទៀត អាជ្ញាធរមូលដ្ឋានគួរសហការជាមួយវិស័យឯកជន ដើម្បីបង្កើត

មជ្ឈមណ្ឌលការងារ និងកម្មវិធីអភិវឌ្ឍជំនាញ ហើយរដ្ឋបាលថ្នាក់ជាតិអាចផ្តល់ការឧបត្ថម្ភធនជាន ឬកម្ចីសម្រាប់បង្កើតអាជីវកម្ម។

- ដើម្បីបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ រដ្ឋបាលថ្នាក់ជាតិគួរតែវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ដូចជាការសាងសង់លំនៅឋានថ្មីនៅទីតាំងដែលមិនមានទឹកលិច ប្រើប្រាស់សម្ភារៈសាងសង់ផ្ទះដែលមានគុណភាព ហើយធន់នឹងអាកាសធាតុនៅទីតាំងថ្មីរបស់ពួកគេ។
- ចំពោះអង្គការសង្គមស៊ីវិល គួររៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របន្សាំខ្លួនទៅនឹងអាកាសធាតុ។
- ការពង្រឹងការអនុវត្តគោលនយោបាយ រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានគួរតែបង្កើតក្របខ័ណ្ឌសម្របសម្រួលដើម្បីត្រួតពិនិត្យ ប្រព័ន្ធវាយតម្លៃផលប៉ះពាល់រយៈពេលវែង និងស្វែងរកការគាំទ្រជាថវិកាពីដៃគូរអភិវឌ្ឍន៍ដើម្បីធានាថាការគោលនយោបាយទាំងនោះអនុវត្តទទួលបានប្រសិទ្ធភាព និងតម្លាភាព។
- ដើម្បីជំរុញបរិយាបន្នសង្គមសម្រាប់គ្រួសារដែលផ្លាស់ប្តូរទៅទីតាំងថ្មី រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូរអភិវឌ្ឍន៍នានា គួរសហការបង្កើតបណ្តាញ និងទំនាក់ទំនងសង្គមឡើងវិញ ដើម្បីធានាថាពួកគេទទួលបានសុវត្ថិភាពផ្លូវចិត្ត និងទំនាក់ទំនងល្អនៅទីតាំងថ្មី។

សរុបមក ការសិក្សានេះបង្ហាញពីតម្រូវការបន្ទាន់សម្រាប់វិធីសាស្ត្ររួមមួយ ក្នុងការដោះស្រាយបញ្ហាប្រឈមដែលទាក់ទងនឹងការផ្តល់សេវាសាធារណៈ និងភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុនៅទីតាំងលំនៅឋានថ្មីក្នុងប្រទេសកម្ពុជា។ កិច្ចសហការប្រកបដោយប្រសិទ្ធភាពក្នុងចំណោមភាគីពាក់ព័ន្ធលើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងការពង្រឹងគោលនយោបាយ ពិតជាមានសារៈសំខាន់ក្នុងការកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមងាយរងគ្រោះ។



*រូបភាពទី២៖ ទិដ្ឋភាពលំនៅឋាននៅភូមិវិហារសួគ៌ជើង ឆ្នាំ២០២៤*

# មាតិកា


**១. សាវតា** . . . . . . **១**

**២. គោលបំណងស្រាវជ្រាវ** . . . . . . **២**

២.១ គោលបំណង . . . . . . ២

២.២ ចំណោទបញ្ហា . . . . . . ២

**៣. វិធីសាស្ត្រស្រាវជ្រាវ** . . . . . . **៣**

**៤. ទិដ្ឋភាពសង្ខេបអំពីសេវាសាធារណៈ និងបញ្ហាបម្រែបម្រួលអាកាសធាតុនៅទីតាំងលំនៅឋានថ្មី** . . . . . . **៤**

**៥. ទិដ្ឋភាពច្បាប់ សិទ្ធិមនុស្ស និងបម្រែបម្រួលអាកាសធាតុ** . . . . . . **៦**

៥.១ អំពីច្បាប់ និងសិទ្ធិមនុស្ស . . . . . . ៦

៥.២ អំពីបម្រែបម្រួលអាកាសធាតុ . . . . . . ៨

៥.៣ ទំនាក់ទំនងសេវាសាធារណៈ និងបម្រែបម្រួលអាកាសធាតុ . . . . . . ៩

៥.៤ លក្ខណៈហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ . . . . . . ១០

**៦. លទ្ធផលស្រាវជ្រាវសំខាន់ៗ** . . . . . . **១២**

៦.១ ទម្រង់ដោះស្រាយសំណងមានលក្ខណៈខុសៗគ្នា . . . . . . ១២

៦.២ ការទទួលបានសេវាសាធារណៈមិនពេញលេញ . . . . . . ១៣

៦.៣ ឱកាសការងារ និងជីវភាព . . . . . . ១៤

៦.៤ ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ . . . . . . ១៤

៦.៥ បញ្ហាប្រឈមចម្បងៗនៃទីតាំងលំនៅឋានថ្មី . . . . . . ១៥

**៧. ការវិភាគ ការរកឃើញសំខាន់ៗ ធៀបនឹងទិដ្ឋភាពច្បាប់ សិទ្ធិមនុស្ស និងបម្រែបម្រួលអាកាសធាតុ** . . . . . . **១៧**

**៨. សេចក្តីសន្និដ្ឋាន** . . . . . . **២០**

**៩. អនុសាសន៍** . . . . . . **២២**

# ១. សាវតា

ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី គឺជាបញ្ហាប្រឈមមួយសម្រាប់ទីតាំងលំនៅឋានក្រីក្រនៅទីក្រុងភ្នំពេញ។ ការអភិវឌ្ឍទីក្រុងយ៉ាងឆាប់រហ័ស និងកំណើននគរូបនីយកម្មបាននាំឱ្យមានការផ្លាស់ទីលំនៅនៃគ្រួសារដែលមានប្រាក់ចំណូលទាបជាច្រើន ដែលជារឿយៗមិនមានសំណងសមរម្យ ឬដំណោះស្រាយសម្រាប់លំនៅឋានដែលល្អប្រសើរនៅឡើយ ខណៈដែលពួកគេមានសិទ្ធិពេញលេញក្នុងការទទួលបានលំនៅឋានសមរម្យ[១]។

ចាប់តាំងពីឆ្នាំ១៩៨០មក ប្រជាពលរដ្ឋច្រើនជាង៤០ ០០០នាក់ ក្នុងរាជធានីភ្នំពេញត្រូវបានបណ្តេញចេញ និងតាំងទីលំនៅថ្មី[២]។ របាយការណ៍ស្ទង់មតិរាជធានីភ្នំពេញក្នុងឆ្នាំ២០២៣ ក៏បានរកឃើញចំនួននៃទីតាំងទីលំនៅឋានក្រីក្រនៅទីក្រុងភ្នំពេញបានថយចុះពីចំនួន២៧៧ទីតាំង នៅឆ្នាំ២០១៧ មកចំនួន១៩១ទីតាំង នៅឆ្នាំ២០២៣ ដោយការថយចុះជាច្រើននេះបណ្តាលមកពីការបណ្តេញចេញដោយបង្ខំ[៣]។ លើសពីនេះទៀត នៅឆ្នាំ២០២៤ បញ្ហានៃការបណ្តេញចេញ និងការគំរាមកំហែងនៅតែបន្តកើតមានឡើងចំពោះទីតាំងលំនៅឋានក្រីក្រនៅទីក្រុងភ្នំពេញ។ យោងតាមរបាយការណ៍របស់អង្គការសមាគមធាងត្នោតដែលចេញផ្សាយដើមឆ្នាំ២០២៤ រកឃើញថា ទីតាំងលំនៅឋានក្រីក្រនៅទីក្រុងចំនួន១១ទីតាំង ដែលរួមមានគ្រួសារចំនួន៨៨៤គ្រួសារ ស្មើនឹងប្រជាពលរដ្ឋចំនួន៣ ៧៩៨នាក់បានប្រឈមនឹងការគំរាមកំហែងនៃការបណ្តេញចេញ[៤]។

ការបណ្តេញចេញទាំងនេះ ជារឿយៗត្រូវបានផ្តល់ហេតុផលថា ជាការចាំបាច់សម្រាប់គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ឬការកែលម្អទីក្រុង។ ទោះជាយ៉ាងណាក៏ដោយ ទីតាំងលំនៅឋានក្រីក្រដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ទាំងនោះ ភាគច្រើនប្រឈមនឹងបញ្ហារួមមាន ការបាត់បង់ការងារ ការបោះបង់ការសិក្សា បញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ និងបញ្ហាទំនាក់ទំនងសង្គម ទឹកស្អាត អនាម័យ និងលទ្ធភាពទទួលបានការថែទាំសុខភាព។

បញ្ហាដែលកំពុងកើតមាននេះ តម្រូវឱ្យអ្នករៀបចំផែនការទីក្រុងត្រូវគិតគូរបន្ថែមទៀតក្នុងការរៀបចំទីក្រុងដែលមានលក្ខណៈបរិយាបន្នដោយគិតអំពីសិទ្ធិ និងតម្រូវការរបស់អ្នករស់នៅទាំងអស់គ្នា ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត។

---

១. អង្គការសមាគមធាងត្នោត ការបណ្តេញចេញ សំណង និងបំណុល ឆ្នាំ២០២៣ តាមរយៈ៖ https://teangtnaut.org/research/reports/Eviction,-Compensation,-and-Debt-Report-2023

២. សមាគមធាងត្នោត ការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ខែមិថុនា ឆ្នាំ២០២០ តាមរយៈ៖ https://teangtnaut.org/research/reports/-Evictions-and-Relocations

៣. អង្គការសមាគមធាងត្នោត ការស្ទង់មតិក្នុងរាជធានីភ្នំពេញ ការសិក្សាទីតាំងលំនៅឋានក្រីក្រក្នុងទីក្រុងភ្នំពេញ ឆ្នាំ២០២៣ តាមរយៈ៖ https://teangtnaut.org/research/reports/THE-PHNOM-PENH-SURVEY-IN-2023:-A-Study-on-Urban-Settlements-in-Phnom-Penh

៤. អង្គការសមាគមធាងត្នោត សុវត្ថិភាពដីធ្លីនៃសហគមន៍ក្រីក្រក្នុងទីក្រុង បញ្ហាប្រឈម និងដំណោះស្រាយ ឆ្នាំ២០២៤ តាមរយៈ៖ https://teangtnaut.org/research/reports/Land-Security-of-Urban-Poor-Communities:-Challenges-and-Solutions-2024

# ២. គោលបំណងស្រាវជ្រាវ

## ២.១ គោលបំណង

ការសិក្សានេះមានគោលបំណង ឈ្វេងយល់អំពីបច្ចុប្បន្នភាពសេវាសាធារណៈនៅទីតាំងលំនៅឋានថ្មីនៃទីតាំងលំនៅឋានក្រីក្រចំនួន៦ ក្នុងរាជធានីភ្នំពេញបានផ្លាស់ទីទៅរស់នៅចន្លោះឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ និងសិក្សាអំពីរបៀបបន្សាំខ្លួនរបស់ពួកគេទៅនឹងបម្រែបម្រួលអាកាសធាតុ ខណៈពេលពួកគេត្រូវការការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ សមធម៌សង្គម និងនិរន្តរភាពបរិស្ថាន។ គោលបំណងជាក់លាក់នៃការសិក្សានេះគឺ៖

- ដើម្បីឈ្វេងយល់អំពីស្ថានភាពនៃការផ្តល់សេវាសាធាណៈក្នុងមូលដ្ឋាន ដល់ទីតាំងលំនៅឋានក្រីក្រដែលមកដល់ទីតាំងលំនៅឋានថ្មី។
- កំណត់ផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលពីការបម្រែបម្រួអាកាសធាតុនៅទីតាំងលំនៅឋានថ្មី។
- ផ្តល់នូវអនុសាសន៍ ការអន្តរាគមន៍នានា ដើម្បីជាដំណោះស្រាយជូនប្រជាពលរដ្ឋនៅទីតាំងលំនៅឋានក្រីក្រ ដែលបានដោះដូរទៅទីតាំងលំនៅឋានថ្មី។

## ២.២ ចំណោទបញ្ហា

- តើសេវាសាធារណៈជាក់លាក់ណាខ្លះដែលមានសារៈសំខាន់បំផុតសម្រាប់អ្នកដែលផ្លាស់ទីតាំងលំនៅឋានថ្មី?
- តើភាពខ្វះចន្លោះក្នុងការផ្តល់សេវាសាធារណៈនៅទីតាំងដែលបានផ្លាស់ទីលំនៅថ្មី នាំឱ្យមានភាពងាយរងគ្រោះយ៉ាងដូចម្តេចខ្លះពីការប្រែប្រួលអាកាសធាតុ?
- តើរាជរដ្ឋាភិបាលបានអនុវត្តន៍យន្តការបែបណាដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋដែលតាំងទីលំនៅឋានថ្មី?
- តើរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធអាចពិចារណាក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះអ្នកផ្លាស់ទីលំនៅឋានថ្មីដោយរបៀបណា?

# ៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ បានប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយរួមបញ្ចូលទាំងវិធីសាស្ត្រស្រាវជ្រាវបែបបរិមាណ និងគុណភាព ដែលរួមមាន ការចុះពិនិត្យនៅទីតាំងផ្ទាល់ កិច្ចពិភាក្សាជាក្រុម កិច្ចសម្ភាសបែបស៊ីជម្រៅជាមួយសមាជិកដែលត្រូវបានផ្លាស់ទីលំនៅឋានថ្មី និងតំណាងប្រជាពលរដ្ឋជាអ្នកភូមិចាស់ដែលរស់នៅក្នុងទីតាំងជាមួយអ្នកផ្លាស់ទីតាំងលំនៅឋានថ្មី។ ដំណើរការស្រាវជ្រាវនេះបានសម្ភាសក្រុមគោលដៅដូចជា ប្រជាពលរដ្ឋមូលដ្ឋានដែលជាអ្នកភូមិចាស់ និងតំណាងសមាជិកដែលជាអ្នកផ្លាស់ទីតាំងលំនៅឋានថ្មី និងរៀបចំកិច្ចពិភាក្សាក្រុម អំពីសេវាសាធារណៈសំខាន់ៗ និងការប្រែប្រួលអាកាសធាតុនៅទីតាំងថ្មី។ ទិន្នន័យដែលបានប្រមូលមកត្រូវបានធ្វើការផ្ទៀងផ្ទាត់ម្តងទៀតតាមរយៈការធ្វើបទបង្ហាញដល់ប្រជាពលរដ្ឋដែលរស់នៅទីតាំងថ្មី។ ទិន្នន័យបន្ទាប់បន្សំដូចជា ឯកសារគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិដែលមានស្រាប់ក៏ត្រូវបានប្រមូលពីប្រភពសំខាន់ៗជាច្រើន ដើម្បីបានជាមូលដ្ឋានក្នុងការវិភាគ និងផ្ទៀងផ្ទាត់ជាមួយនឹងលទ្ធផលស្រាវជ្រាវសំខាន់ៗ។ កិច្ចការស្រាវជ្រាវនេះនឹងបង្ហាញអំពីបទពិសោធន៍បញ្ហាប្រឈមនានារបស់អ្នករស់នៅទីតាំងថ្មី និងជាឯកសារគោលសម្រាប់អ្នករៀបចំគោលនយោបាយដែលទាក់ទងទៅនឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មីដែលប៉ះពាល់ដោយគម្រោងអភិវឌ្ឍន៍។

*តារាងទី១៖ទីតាំងលំនៅឋានក្រីក្រដែលជ្រើសរើសមកសិក្សា*

| ល.រ | ឈ្មោះទីតាំងលំនៅឋានក្រីក្រនៅទីតាំងចាស់ | ទីតាំថ្មី | | | |
|---|---|---|---|---|---|
| | | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ខណ្ឌ | ខេត្ត/ក្រុង |
| ១ | បន្ទាយស្លឹក | វិហារសួគ៌ជើង | វិហារសួគ៌ | ខ្សាច់កណ្តាល | កណ្តាល |
| ២ | បឹងតាមោក (ទីតាំងទី១) | ទួលពន្សាំង | ពន្សាំង | ព្រែកព្នៅ | ភ្នំពេញ |
| ៣ | បឹងតាមោក (ទីតាំងទី២) | ស្រែដូនតូច | ពន្សាំង | ព្រែកព្នៅ | ភ្នំពេញ |
| ៤ | ផ្លូវរថភ្លើង | បឹងសាឡាង និងដើមចន្ទ | ទួលសង្កែ | ឫស្សីកែវ | ភ្នំពេញ |
| ៥ | ទួលសង្កែ | ដើមចន្ទ(ក្រោលគោ) | គីឡូម៉ែត្រលេខ៦ | ឫស្សីកែវ | ភ្នំពេញ |
| ៦ | ចំរើនអភិវឌ្ឍ (ព្រែកប្រា) | ចំពុះក្អែក | ព្រែកថ្មី | ច្បារអំពៅ | ភ្នំពេញ |

# ៤.ទិដ្ឋភាពសង្ខេបអំពីសេវាសាធារណៈ និងបញ្ហាបម្រែបម្រួលអាកាសធាតុនៅទីតាំងលំនៅឋានថ្មី

ស្ថានភាពអាកាសធាតុនៅទីតាំងលំនៅឋានក្រីក្រទាំង៦ ដែលបានផ្លាស់ទៅទីតាំងថ្មីចន្លោះពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៣ បានជួបប្រទះរួមមាន ការកើនឡើងកម្ដៅ និងបញ្ហាប្រឈមចម្បងៗ។ ប្រភេទលំនៅឋានរបស់ពួកគេរស់នៅអាចកំណត់បានជា ៤ប្រភេទ៖ ប្រភេទទី១៖ ផ្ទះជញ្ជាំងឈើ និងដំបូលស័ង្កសី ប្រភេទទី២៖ ផ្ទះជញ្ជាំងស័ង្កសី និងដំបូលស័ង្កសី ប្រភេទទី៣៖ ផ្ទះជញ្ជាំងថ្ម និងដំបូលស័ង្កសី និងប្រភេទទី៤៖ ផ្ទះជញ្ជាំងថ្ម និងដំបូលក្បឿង។ នៅពេលមកផ្លាស់ទីលំនៅដំបូង ទីតាំងលំនៅថ្មីស្ទើរតែទាំងអស់មិនទាន់មានផ្លូវបេតុង និងប្រព័ន្ធលូទេ ហើយប្រព័ន្ធទឹកស្អាត និងអគ្គិសនីក៏មិនបានរៀបចំរួចជាស្រេចមុនការមកតាំងទីលំនៅរបស់ពួកគេដែរ ខណៈពេលដែលប្រព័ន្ធទាំងអស់នេះគួរត្រូវបានរៀបចំឡើងជាស្រេចមុនពេលពួកគេមកដល់។ នៅទីតាំងមួយចំនួនបានចំណាយថវិកាផ្ទាល់ខ្លួនដើម្បីភ្ជាប់ប្រព័ន្ធទឹកស្អាត និងអគ្គិសនីដែលបានចំណាយច្រើនបំផុតចន្លោះពី១២ ទៅ២៧ ម៉ឺនរៀល។ ខណៈពេលពួកគេមានជីវភាពក្រីក្រនៅឡើយ គ្រួសារភាគច្រើនដែលបានសម្ភាសបានអះអាងថា ពួកគេមិនទទួលបានប្រព័ន្ធគាំពារសង្គមដូចជាប័ណ្ណសមធម៌នោះទេ។ ជាក់ស្ដែងស្ត្រីវ័យចំណាស់ម្នាក់បានជួបគ្រោះថ្នាក់ចរាចរណ៍បណ្ដាលឱ្យបាក់ជើងស្ដាំ ដោយគ្មានលទ្ធភាពព្យាបាលនៅមន្ទីរពេទ្យបង្អែក ឬឯកជន គាត់បានខ្ចីលុយអ្នកជិតខាងចំនួន ៤០ម៉ឺនរៀល សម្រាប់ព្យាបាលជាមួយគ្រូខ្មែរ[៥] ខណៈពេលប័ណ្ណសមធម៌ដែលធ្លាប់ប្រើប្រាស់នៅទីតាំងចាស់ផុតសុពលភាពមិនអាចប្រើប្រាស់បាននៅទីតាំងថ្មី។ ម្យ៉ាងវិញទៀត បញ្ហាប្រឈមចម្បងទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ គឺរងផលប៉ះពាល់ខ្លាំងពីការកើនកម្ដៅ និងបញ្ហាទឹកកខ្វក់ ជាដើម ជាពិសេសនៅរដូវវស្សា។

៥. គ្រូខ្មែរ ជាគ្រាមភាសារក្នុងតំបន់ដែលអ្នកស្រុកធ្លាប់ហៅ ឬម្យ៉ាងទៀតអាចហៅបានថា ជាគ្រូខ្មែរបុរាណ ដែលចេះចាំវិធីសាស្រ្តព្យាបាលជំងឺ ឬតម្លឹងតៗគ្នាតាមរបៀបបុរាណ។




*រូបភាពទី៣៖ លំនៅឋាននៅភូមិទួលពន្សាំងដែលត្រូវបានដាក់លក់ ដោយម្ចាស់ផ្ទះទៅធ្វើការនៅខេត្តផ្សេង ឆ្នាំ២០២៥*

# ៥. ទិដ្ឋភាពច្បាប់ សិទ្ធិមនុស្ស និង បម្រែបម្រួលអាកាសធាតុ

## ៥.១ អំពីច្បាប់ និងសិទ្ធិមនុស្ស

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៦] បានកំណត់យ៉ាងច្បាស់ចំពោះប្រជាពលរដ្ឋគ្រប់រូបមានមានសិទ្ធិស្មើគ្នាជាពិសេស សិទ្ធិមានលំនៅឋានសមរម្យ និងសិទ្ធិរស់រានមានជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរ[៧]។ ដើម្បីធានាបាននូវសិទ្ធិសំខាន់ៗទាំងនេះ និងជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្តែងនៅប្រទេសកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចបង្កើត "គោលនយោបាយជាតិ ស្តីពីលំនៅឋាន" ក្នុងឆ្នាំ២០១៤[៨]។ គោលនយោបាយនេះមានគោលបំណង ដោះស្រាយលំនៅឋានជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត ដើម្បីអាចទទួលបានជីវិតរស់នៅប្រកបដោយសុវត្ថិភាព សុខមាលភាព និងសេចក្តីថ្លៃថ្នូរ។ ក្នុងចំណោមជម្រើសទាំង៩ នៃជម្រើសដើម្បីទទួលបានលំនៅឋានក្នុងគោលនយោបាយនេះ មានជម្រើសពីរសំខាន់ គឺជម្រើសទី១៖ លំនៅឋានមានតម្លៃសមរម្យ និងជម្រើសទី៦៖ ការប្តូរទីតាំងទៅកាន់កន្លែងថ្មី ដែលគួរវិភាគចំពោះទីតាំងលំនៅឋានក្រីក្រដែលជ្រើសមកសិក្សាក្នុងរបាយការណ៍នេះ។ ជម្រើសទី១ រាជរដ្ឋាភិបាលអាចសាងសង់លំនៅឋានសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមងាយរងគ្រោះដោយសាងសង់លំនៅឋានតម្លៃទាបសម្រាប់លក់ក្នុងតម្លៃសមរម្យនិង/ឬឱ្យបង់រំលស់រយៈពេលវែង។ ជម្រើសទី៦ ការតាំងទីលំនៅថ្មីគួររៀបចំនៅកន្លែងជិតទីប្រជុំជន ដែលអាចមានហេដ្ឋារចនាសម្ព័ន្ធ និងសេវានានាជាមូលដ្ឋានអាចមានលក្ខខណ្ឌងាយស្រួលក្នុងការរកការងារធ្វើ និងធានាបាននូវសុវត្ថិភាពក្នុងការរស់នៅ។

កម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) បានកំណត់លក្ខណៈវិនិច្ឆ័យជាអប្បបរមាលើលំនៅឋានសមរម្យនូវ៧ ចំណុចរួមមាន[៩]៖

- សុវត្ថិភាពក្នុងការកាន់កាប់៖ លំនៅឋានមិនមានលក្ខណៈសមរម្យនៅឡើយប្រសិនបើអ្នកកាន់កាប់ មិនមានសុវត្ថិភាពក្នុងការកាន់កាប់ដែលធានាដល់ការការពារផ្លូវច្បាប់ប្រឆាំងនឹងការបណ្តេញចេញដោយបំពាន ការយាយីរំខាន និងការគំរាមកំហែងដទៃទៀត។
- ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អគារ ឬកន្លែងផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធ៖ លំនៅឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើអ្នកកាន់កាប់ មិនមានទឹកពិសារសុវត្ថិភាព (ទឹកស្អាត) អនាម័យ ថាមពលគ្រប់គ្រាន់សម្រាប់ចម្អិនអាហារ ប្រព័ន្ធកម្តៅ ឧបករណ៍សម្រាប់បំភ្លឺ មធ្យោបាយរក្សាទុកម្ហូបអាហារ ឬកន្លែងចាក់កាកសំណល់។

---

៦. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ តាមរយៈ៖ https://constitution.ccc.gov.kh/preahreachokram.php
៧. អង្គការសហប្រជាជាតិ សិទ្ធិមានលំនៅឋានសមរម្យ សេចក្តីរាយការណ៍ពិសេសស្តីពីសិទ្ធិទទួលបានលំនៅដ្ឋានសមរម្យ តាមរយៈ៖ https://www.ohchr.org/en/special-procedures/sr-housing/human-right-adequate-housing
៨. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គោលនយោបាយជាតិស្តីពីលំនៅឋាន ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ តាមរយៈ៖ គោលនយោបាយជាតិស្តីពីលំនៅឋាន – ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (mlmupc.gov.kh)
៩. ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប័ណ្ណព័ត៌មានលេខ២១ ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ ខែធ្នូ ឆ្នាំ២០១២ តាមរយៈ៖ The Right to Adequate Housing (ohchr.org)

- **ភាពអាចលៃលកបាន៖** លំនៅឋានមិនមានលក្ខណៈសមរម្យឡើយប្រសិនបើតម្លៃរបស់លំនៅឋាននោះ គំរាមកំហែង ឬបង្កឧបសគ្គដល់អ្នកកាន់កាប់ក្នុងការប្រើប្រាស់សិទ្ធិមនុស្សផ្សេងទៀត។
- **ភាពអាចរស់នៅបាន៖** លំនៅឋានមិនមានលក្ខណៈសមរម្យឡើយប្រសិនបើលំនៅឋាននោះ មិនមានសុវត្ថិភាពរូបកាយ ឬមានទីធ្លាធំទូលាយគ្រប់គ្រាន់ ព្រមទាំងការពារការទប់ទល់នឹងអាកាសធាតុត្រជាក់ សើម កម្ដៅ ភ្លៀង ខ្យល់ ការគំរាមកំហែងដទៃទៀតដល់សុខភាព និងអន្តរាយផ្នែករចនាសម្ព័ន្ធ។
- **ភាពអាចប្រើប្រាស់បាន៖** លំនៅឋានមិនមានលក្ខណៈសមរម្យឡើយ ប្រសិនបើសេចក្ដីត្រូវការជាក់លាក់របស់ក្រុមងាយរងគ្រោះ និងទីទាល់ក្របំផុតមិនត្រូវបានគិតគូរដល់នោះទេ។
- **ទីតាំង៖** លំនៅឋានមិនមានលក្ខណៈសមរម្យឡើយប្រសិនបើ ទីតាំងនោះផ្ដាច់ចេញពីឱកាសការងារ សេវាថែទាំសុខភាព សាលារៀនមជ្ឈមណ្ឌលគាំពារកុមារ និងសេវាសង្គមដទៃទៀត ឬប្រសិនបើលំនៅឋាននោះស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់ ឬមានការបំពុលបរិស្ថាន។
- **ភាពសមស្របផ្នែកវប្បធម៌ និងប្រពៃណី៖** លំនៅឋានមិនមានលក្ខណៈសមរម្យឡើយប្រសិនបើលំនៅឋាននោះ មិនគោរព និងគិតគូរពីអត្តសញ្ញាណវប្បធម៌។

លើសពីនេះទៀតការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ក៏បានចេញផ្សាយ "គោលការណ៍ណែនាំ ស្ដីពីការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី" ដែលក្នុងនោះមានចំណុចសំខាន់គួរត្រូវបានពិចារណាក្នុងផ្នែក "*បន្ទាប់ពីការបណ្ដេញចេញ*" ដែលផ្ដោតទៅលើ "*ជំនួយបន្ទាន់ និងការតាំងទីលំនៅថ្មី*"។ ក្នុងចំណុចនេះ បញ្ជាក់ពីទំនួលខុសត្រូវរបស់រាជរដ្ឋាភិបាលក្នុងការផ្ដល់សំណងសមរម្យ និងការស្រុះស្រួលសមស្របផ្សេងទៀត ឬការធ្វើឱ្យដូចដើមវិញប្រសិនជាអាចធ្វើបាន ត្រូវតែធ្វើឱ្យបានយ៉ាងឆាប់បំផុតក្រោយពីការបណ្ដេញចេញ លើកលែងតែការឱ្យចាកចេញក្នុងករណីប្រធានសក្តិ។ បុគ្គល ឬក្រុមដែលត្រូវបានគេបណ្ដេញចេញជាពិសេសអ្នកដែលគ្មានលទ្ធភាពដោយផ្ទាល់ខ្លួនដូចជាសហគមន៍ក្រីក្រត្រូវបានធានាថាគ្មានការរើសអើងពីអាជ្ញាធរមានសមត្ថកិច្ច ហើយក្រុមងាយរងគ្រោះនេះ មានសិទ្ធិទទួលបានជាប់លាប់ និងមានសុវត្ថិភាពនូវ (ក) អាហារចាំបាច់ ទឹកស្អាត និងអនាម័យ (ខ) ជម្រក និងផ្ទះសម្បែងជាមូលដ្ឋាន (គ) សម្លៀកបំពាក់សមរម្យ (ឃ) សេវាវេជ្ជសាស្ត្រចាំបាច់ (ង) ប្រភពសម្រាប់ចិញ្ចឹមជីវិត (ច) ចំណីសត្វ និងការប្រើប្រាស់ប្រភពទ្រព្យសម្បត្តិរួម ដែលពួកគេបានពឹងអាស្រ័យកន្លងមក និង (ឆ) ការអប់រំបុត្រធីតា និងកន្លែងគាំពារកុមារ។ ក្នុងផ្នែកនេះក៏បានបញ្ជាក់ផងដែរថា រដ្ឋមិនត្រឹមតែមានទំនួលខុសត្រូវក្នុងការផ្ដល់សំណងសមរម្យប៉ុណ្ណោះទេ ប៉ុន្តែរដ្ឋគួរធានាផងដែរថា សមាជិកខ្សែស្រឡាយគ្រួសារ ឬសហគមន៍តែមួយជាមួយគ្នា មិនត្រូវបានបំបែកឱ្យនៅទីទៃពីគ្នាដោយសារតែការបណ្ដេញចេញឡើយ[១០]។

១០. ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា សេចក្ដីអត្ថាធិប្បាយរបស់អង្គការសហប្រជាជាតិ គោលការណ៍ណែនាំស្ដីពី ការបណ្ដេញចេញ និងការតាំងទីលំនៅថ្មី ខែមិថុនា ឆ្នាំ២០១៣ តាមរយៈ៖ https://cambodia.ohchr.org/kh/content/united-nations-commentary-and-guidelines-eviction-and-resettlement

## ៥.២ អំពីបម្រែបម្រួលអាកាសធាតុ

បច្ចុប្បន្ន បម្រែបម្រួលអាកាសធាតុគឺជាបញ្ហាប្រឈមដ៏ចម្បងចំពោះពិភពលោក ហើយផលប៉ះពាល់ដែលកើតចេញពីបញ្ហានេះ ជះឥទ្ធិពលយ៉ាងខ្លាំងចំពោះការរស់នៅរបស់មនុស្សជាតិ[១១]។ លើសពីនេះទៀត រដ្ឋបាលជាតិ ស្តីពីមហាសមុទ្រ និងបរិយាកាស (National Oceanic and Atmospheric Administration) រកឃើញថា សីតុណ្ហភាពសកលបានកើនឡើង ១,១ អង្សាសេ (C°) ចាប់តាំងពីឆ្នាំ១៨៥០ ដល់ឆ្នាំ២០២៣ ដែលប៉ះពាល់យ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋនៅលើពិភពលោក។ គួរឱ្យកត់សម្គាល់ផងដែរថា ក្នុងចំណោមពួកគេ គឺក្រុមងាយរងគ្រោះរងផលប៉ះពាល់ជាងគេដោយសារតែវិសមភាពសង្គម[១២]។

ស្រដៀងគ្នានេះដែរក្រុមប្រឹក្សាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានព្រមានថា ហានិភ័យនៃបម្រែបម្រួលអាកាសធាតុនឹងកាន់តែធ្ងន់ធ្ងរជាងការរំពឹងទុក ដែលមានមនុស្សចំនួន ៣,៦ ពាន់លាននាក់កំពុងរស់នៅក្នុងតំបន់ដែលងាយរងគ្រោះខ្លាំងពីការប្រែប្រួលអាកាសធាតុ។ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានប្រាក់ចំណូលទាប បានរងផលប៉ះពាល់គួឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងអត្រាមរណភាពដោយសារការកើនឡើងនៃកម្តៅខ្ពស់ជាង ១៥ ដងនៅក្នុងតំបន់ដែលងាយរងគ្រោះ។ អង្គការសុខភាពពិភពលោកកំពុងដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសុខភាព ជាពិសេសនៅអាស៊ីក្នុងគោលបំណងសម្រេចបានការធានារ៉ាប់រងសុខភាពជាសកល (UHC)។ បម្រែបម្រួលអាកាសធាតុកំពុងធ្វើឱ្យកើនឡើងនូវ ជំងឺអត្រាមរណៈ ជំងឺដែលបង្កឡើងដោយអាហារ គំរាមកំហែងដល់ការទទួលបានសេវាសុខាភិបាល និងបង្កឱ្យមានភាពអត់ឃ្លាន និងអសន្តិសុខស្បៀង[១៣]។

ប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មួយនៅអាស៊ី ដែលកំពុងរងផលប៉ះពាល់យ៉ាងខ្លាំងពីការប្រែប្រួលអាកាសធាតុ ដែលមានន័យថាជាតម្រូវការបន្ទាន់ក្នុងការសម្របខ្លួនទៅនឹងផលប៉ះពាល់ដែលកើតមានឡើង។ បើគ្មានវិធានការសម្របខ្លួន និងកាត់បន្ថយការប្រែប្រួលអាកាសធាតុបានល្អនោះទេ កម្ពុជាអាចចំណាយរហូតដល់ ៩ភាគរយនៃផលិតផលជាតិក្នុងស្រុកសរុបនៅឆ្នាំ២០៥០ ខណៈពេលដែលអត្រាភាពក្រីក្រអាចកើនរហូតដល់ ៦ភាគរយនៅឆ្នាំ២០៤០[១៤]។ ការរកឃើញនេះ ជាបញ្ហាគួរឱ្យកត់សម្គាល់មួយសម្រាប់ទីតាំងលំនៅឋានក្រីក្រ ឬក្រុមងាយរងគ្រោះនៅទីក្រុងផងដែរ ដែលពួកគេមិនត្រឹមតែរងផលប៉ះពាល់ពីបម្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងកង្វះលទ្ធភាពទទួលបានលំនៅឋានសមរម្យថែមទៀតផង។ ជាក់ស្តែងតាមរយៈរបាយការណ៍របស់អង្គការលំនៅឋានមនុស្សជាតិកម្ពុជាក្នុងឆ្នាំ២០២៣ រកឃើញថា ៤០ភាគរយ នៃប្រជាពលរដ្ឋក្នុងទីក្រុងរស់នៅតំបន់មិនទាន់រៀបរយ[១៥]។

---

១១. អេន អ ឌី ស៊ី (NRDC) តើបម្រែបម្រួលមានផល់ប៉ះពាល់អ្វីខ្លះ? ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២ តាមរយៈ៖ https://www.nrdc.org/stories/what-are-effects-climate-change

១២. រដ្ឋបាលជាតិ ស្តីពីមហាសមុទ្រ និងបរិយាកាស (NOAA) ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ តាមរយៈ៖ https://www.noaa.gov/education/resource-collections/climate/climate-change-impacts

១៣. អង្គការសុខភាពពិភពលោក បម្រែបម្រួលអាកាសធាតុ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៣ តាមរយៈ៖ https://www.who.int/news-room/fact-sheets/detail/climate-change-and-health

១៤. ធនាគាពិភពលោក (World Bank) របាយការណ៍អាកាសធាតុ និងការអភិវឌ្ឍប្រទេសកម្ពុជា (ភាសាអង់គ្លេស) ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ តាមរយៈ៖ http://documents.worldbank.org/curated/en/099092823045083987/P17887106c6c2d0e909aa1090f3e10505c1

១៥. អង្គការលំនៅឋានមនុស្សជាតិកម្ពុជា លំនោឋានសម្រាប់មនុស្សជាតិនៅកម្ពុជា តាមរយៈ៖ https://shorturl.at/xWZed

## ៥.៣ ទំនាក់ទំនងសេវាសាធារណៈ និងបម្រែបម្រួលអាកាសធាតុ

កំណើនប្រជាជន និងនគរូបនីយកម្ម ជាដំណើរវិវត្តឥតឈប់ឈរនៃទីក្រុងនៅទូទាំងពិភពលោក ដែលនាំឱ្យមានបញ្ហាចម្បងរួមមាន កត្តាបម្រែបម្រួលអាកាសធាតុ វិសមភាពសង្គម និងបញ្ហាផ្នែកសេដ្ឋកិច្ច។ បញ្ហាប្រឈមទាំងនេះតម្រូវឱ្យមានការគិតគូរអំពីដំណោះស្រាយទាន់ពេលវេលា ដើម្បីអាចឱ្យពិភពលោកសម្រេចបាននូវគោលដៅអភិវឌ្ឍដោយចីរភាព។

បច្ចុប្បន្ន ច្រើនជាងពាក់កណ្ដាលនៃប្រជាជនទូទាំងពិភពលោក ដែលត្រូវបានប៉ាន់ប្រមាណថានឹងកើនឡើងរហូតដល់ ២,៤ ពាន់លាននាក់ត្រឹមឆ្នាំ២០៥០។ ការកើនឡើងនៃចំនួនប្រជាជនដ៏ច្រើនបែបនេះជាកត្តាជំរុញឱ្យមានការពង្រីកទីក្រុងយ៉ាងឆាប់រហ័ស ដែលទន្ទឹមនឹងការរីកចម្រើននេះនាំឱ្យមានបញ្ហាប្រឈមសម្រាប់រាជរដ្ឋាភិបាលផងដែរ។ ជាងនេះទៅទៀត ការអភិវឌ្ឍទីក្រុងដែលមិនមានផែនការច្បាស់លាស់ជាការរួមចំណែកនាំឱ្យមានការជះឥទ្ធិពលអវិជ្ជមានដល់ការប្រែប្រួលអាកាសធាតុ ខណៈការកើនឡើងនៃតម្រូវការលំនៅឋាន ដែលមានមនុស្សច្រើនជាង ១,១ ពាន់លាននាក់[១៦]។ លើសពីនេះទៀត កម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ ដែលចេញផ្សាយរបាយការណ៍នៅឆ្នាំ២០២៤ បានប៉ាន់ប្រមាណអត្រាអ្នករស់នៅក្នុងទីក្រុងច្រើនជាង ២ពាន់លាននាក់នឹងប្រឈមការកើនឡើងកម្ដៅនៅឆ្នាំ ២០៤០។ អ្នកទាំងនោះភាគច្រើនជាក្រុមងាយរងគ្រោះ និងប្រជាពលរដ្ឋដែលរស់នៅតំបន់មិនរៀបរយដែលងាយរងផលប៉ះពាល់ខ្លាំងជាងគេពីការប្រែប្រួលអាកាសធាតុ[១៧]។

ដូចនេះ កំណើននៃមនុស្សជាតិទូទាំងសកលលោក និងការរីកលូតលាស់នៃទីក្រុង គឺជាដំណើរវិវត្តទៅមុខជានិច្ចដែលមិនអាចហាមឃាត់បាន។ ការរៀបចំផែនការអភិវឌ្ឍទីក្រុងឱ្យបានច្បាស់លាស់សម្រាប់រយៈពេលវែងគឺជាការចាំបាច់ ក្នុងការធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងអាចឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមងាយរងគ្រោះ ប្រជាពលរដ្ឋរស់នៅតំបន់មិនរៀបរយ និងទីតាំងលំនៅឋានក្រីក្រដែលត្រូវបានតាំងទីលំនៅឋានថ្មី គួរត្រូវបានយកចិត្តទុកដាក់ខ្លាំងក្នុងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានឱ្យបានគ្រប់គ្រាន់ ជាពិសេសការរៀបចំនេះ ត្រូវមានលក្ខណៈផ្សារភ្ជាប់ទំនាក់ទំនងសង្គម និងមានភាពបៃតងចម្រុះដែលអាចទប់ទល់ទៅនឹងបម្រែបម្រួលអាកាសធាតុបានល្អ។ ជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ កម្ពុជាក៏បានរៀបចំ "*ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព សម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០*"[១៨] ដែលជាផែនទីបង្ហាញផ្លូវមួយសម្រាប់អ្នករៀបចំគោលនយោបាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិនានា ដើម្បីបន្តការអភិវឌ្ឍទីក្រុងដែលមានកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងពង្រឹងបរិយាបន្នសង្គម ក្នុងគោលដៅប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ។ ទោះជាយ៉ាងណាក៏ដោយ ទីតាំងលំនៅឋានក្រីក្រដែលតាំងទីលំនៅឋានថ្មីភាគច្រើន មិនទាន់ទទួលបានការអភិវឌ្ឍលំនៅឋាន និងហេដ្ឋារចនាសម្ព័ន្ធ

១៦. រ៉ូស៍បាក (Rossbach) ខណៈទីក្រុងលើសកលលោករីកលូតលាស់យ៉ាងឆាប់រហ័ស មនុស្សត្រូវតែមានផែនការច្បាស់លាស់ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ តាមរយៈ៖ https://time.com/7203147/sustainable-urban-development/

១៧. UN-Habitat របាយការណ៍ទីក្រុងទូទាំងសកលោក ឆ្នាំ២០២៤ ទីក្រុង និងសកម្មភាដើម្បីអាកាសធាតុ ឆ្នាំ ២០២៤ តាមរយៈ៖ https://unhabitat.org/sites/default/files/2024/11/wcr2024_-_full_report.pdf

១៨. ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព (NCSD, GGGI & ICEM) ផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ២០១៨-២០៣០ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៤ តាមរយៈ៖ Sustainable City Plan for Phnom Penh 2018-2030_En

បានល្អប្រសើរនៅឡើយ ដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយឱ្យទាន់ពេលវេលា ដើម្បីធានាថាការរស់នៅរបស់ពួកគេអាចបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុបានល្អ។ ដូចនេះបញ្ហាប្រឈមដែលពួកគេកំពុងជួបប្រទះគួរត្រូវបានដោះស្រាយឱ្យទាន់ពេលវេលា។

## ៥.៤ លក្ខណៈនៃហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ

កំណើនយ៉ាងឆាប់រហ័សនៃចំនួនប្រជាជននៅទីក្រុង និងនគរូបនីយកម្ម មានទំនាក់ទំនងគ្នាក្នុងការរៀបចំផែនការដីធ្លីសម្រាប់ទីក្រុងដែលមានតុល្យភាពរវាង ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងកិច្ចការពារបរិស្ថាន។ ការរស់នៅក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុជារឿងដែលប្រជាពលរដ្ឋគ្រប់រូបមិនអាចជៀសវៀងបាន ប៉ុន្តែការរៀបចំផែនការ និងវិធីសាស្ត្របន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីធានាថាការរស់នៅរបស់ពលរដ្ឋគ្រប់រូបទទួលបានភាពធន់ ជាពិសេសក្រុមងាយរងគ្រោះ និងទីតាំងលំនៅឋានក្រីក្រដែលតាំងទីលំនៅឋានថ្មី។ តម្រូវការសំខាន់ៗរបស់ពួកគេរួមមាន ហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋាន និងលំនៅឋានដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងលំនៅឋាន ដែលអាចឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុបាន រួមមាន៦ចំណុចសំខាន់ៗ[១៩]។

- ***ទី១ ការរចនាប្លង់លំនៅឋានដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ៖*** លំនៅឋានគួរត្រូវបានសាងសង់ដោយមានការគិតគូរអំពី ប្លង់នៃការសាងសង់ និងទិសដៅ លំហូរខ្យល់ធម្មជាតិ បង្អួច និងម្លប់នៃសំយាបផ្ទះ សម្ភារៈពណ៌ស្រាល និងពិដានអ៊ីសូឡង់។ ការសាងសង់លំនៅឋានតាមលំនាំទាំងនេះអាចជួយឱ្យការរស់នៅមានផាសុខភាព និងបរិយាកាសល្អ។
- ***ទី២ កាត់បន្ថយការចំណាយលើថាមពល៖*** ការគិតគូរអំពីថ្លៃចំណាយលើថាមពល មិនត្រឹមតែអាចកាត់បន្ថយការចំណាយថវិកាប្រចាំថ្ងៃប៉ុណ្ណោះទេ តែថែមទាំងជួយកាត់បន្ថយការប្រើប្រាស់ថាមពលដូចជាអគ្គិសនីជាដើម ដែលថាមពលអគ្គិសនីភាគច្រើនរួមចំណែកធ្វើឱ្យមានការកើនឡើងផលជះអវិជ្ជមាននៃបម្រែបម្រួលអាកាសធាតុ។ ដូចនេះក្នុងការកាត់បន្ថយការចំណាយលើថាមពល អាចអនុវត្តបានតាមបីវិធីដូចជា ទី១៖ការប្រើប្រាស់ពន្លឺធម្មជាតិដោយប្រើប្រាស់ដំបូលថ្លា ឬដំបូលជំនួសអំពូលអគ្គិសនី ទី២៖ការរចនាលំនៅឋានដែលអនុញ្ញាតឱ្យពន្លឺធម្មជាតិចេញចូលបានគ្រប់គ្រាន់ និងទី៣៖ ការប្រើប្រាស់ថាមពលសូឡា។
- ***ទី៣ សម្ភារៈកែច្នៃឡើងវិញ និងបញ្ចេញកាបូនទាប៖*** សម្ភារៈមួយចំនួនដែលអាចកែច្នៃ ឬជាវត្ថុធាតុដើមដែលមានតម្លៃទាបគួរត្រូវបានពិចារណាដើម្បីយកមកសាងសង់លំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប។ សម្ភារៈទាំងនោះអាចត្រូវបានជ្រើសរើសយកមកប្រើប្រាស់តាមលទ្ធភាព និងភាពអាចរកបានជាក់ស្តែង ដែលរួមមាន ឫស្សី ឬតម្បាញធម្មជាតិដែលអាចប្រើប្រាស់សម្រាប់ធ្វើជាជញ្ជាំង ពិដាន ឬនៅទីតាំងផ្សេងៗទៀតនៃលំនៅឋាន។ បន្ថែមពីនេះទៀត ឥដ្ឋខ្យល់

---

១៩. សមាគមធាងត្នោត សៀវភៅណែនាំសម្រាប់សហគមន៍ក្រីក្រក្នុងប្រទេសកម្ពុជា គោលការណ៍ណែនាំអំពី អាកាសធាតុឆ្លាតវៃ តាមរយៈ៖ https://app.teangtnaut.org/storage/attachments/332/Climate-Smart-Design-Guidelines_MIS-SCCF--STT.pdf

និងឥដ្ឋអេកូ ក៏អាចជាជម្រើសមួយក្នុងការសាងសង់ជញ្ជាំងលំនៅឋាន។ ឥដ្ឋទាំងនេះមានសមត្ថភាពក្នុងការទប់ទល់នឹងកម្តៅបានល្អក្នុងការរក្សាភាពត្រជាក់ក្នុងលំនៅឋាន។ ម៉្យាងទៀតការប្រើប្រាស់ឥដ្ឋអេកូ ក៏ជាការរួមចំណែកក្នុងជួយបរិស្ថានផងដែរ ព្រោះសំរាម សំណល់រឹងជាវត្ថុធាតុដើមត្រូវបានកែច្នៃសម្រាប់ផលិតឥដ្ឋនេះ។ លើសពីនេះទៀត ដបថ្ម ឬដបប្លាស្ទិកក៏អាចយកមកសាងសង់ជាជញ្ជាំងផ្ទះមួយផ្នែកផងដែរ ដែលវត្ថុធាតុដើមនេះអាចរកបានដោយងាយ និងមានតម្លៃថោក។

- ❑ *ទី៤ ការគ្រប់គ្រងសំរាម សំណល់រឹង៖* ការប្រើប្រាស់ឡើងវិញ ការកាត់បន្ថយ និងការកែច្នៃឡើងវិញ នៃសំរាម សំណល់រឹង ជាយុទ្ធសាស្ត្រមួយដែលមានប្រសិទ្ធភាព និងពេញនិយមក្នុងការកាត់បន្ថយការចំណាយប្រចាំថ្ងៃ និងបម្រែបម្រួលអាកាសធាតុ។ នៅក្នុងយុទ្ធសាស្ត្រនេះ មានវិធីមួយចំនួនដែលអាចធ្វើបានរួមមានការកំណត់ទីតាំងទុកដាក់សំរាមរួម ការកែច្នៃសំណល់ផ្ទះបាយទៅជាជីកំប៉ុស្ត៍ និងឡជីវឧស្ម័ន។ វិធីទាំងនេះអាចជួយឱ្យបរិស្ថាននៅមូលដ្ឋានស្អាត ជួយកាត់បន្ថយបម្រែបម្រួលអាកាសធាតុ និងជីវិតរស់នៅមានផាសុខភាព។
- ❑ *ទី៥ ទឹកស្អាត និងអនាម័យ៖* គឺជាកត្តាសំខាន់ និងចាំបាច់សម្រាប់គ្រប់គ្នា។ ដំបូលផ្ទះនីមួយៗគួរត្រូវបានរៀបចំ ដែលអាចទាញយកទឹកភ្លៀងធម្មជាតិសម្រាប់ស្តុកទុកបាន ហើយធុងចម្រោះទឹកស្អាតគួរតែត្រូវបានប្រើប្រាស់ដើម្បីធានាថាទឹកមានសុវត្ថិភាព និងមិនប៉ះពាល់ដល់សុខភាព។ វិធីនេះមានប្រសិទ្ធភាពសម្រាប់ទីតាំងដែលមិនមានប្រព័ន្ធទឹកស្អាតប្រើប្រាស់។ ម៉្យាងទៀតប្រព័ន្ធរំដោះទឹក ដូចជាលូបង្ហូរទឹកក៏គួរត្រូវបានរៀបចំឱ្យមានល្អប្រសើរផងដែរ ដើម្បីកុំឱ្យមានទឹកស្អុយដក់នៅតាមលំនៅឋាន និងរក្សាបានអនាម័យ។
- ❑ *ទី៦ ការរៀបចំសួនច្បារតូចៗ៖* ជាជម្រើសដ៏ល្អមួយដែលងាយស្រួលធ្វើ និងចំណាយថវិកាតិចប៉ុន្តែមានប្រសិទ្ធភាពខ្ពស់សម្រាប់សុខុមាលភាពក្នុងការរស់នៅសម្រាប់លំនៅឋានដែលមិនមានទីធ្លាធំទូលាយ។ សួនច្បារតូចៗទាំងនោះអាចធ្វើអំពីដប និងកែវប្លាស្ទិកចាស់ៗដែលប្រើប្រាស់រួចចងតម្រៀបគ្នាទៅតាមស្ថានភាពជាក់ស្តែង។ បន្ថែមពីនេះទៀត ការប្រើប្រាស់ការ៉ុងចាស់អាចជំនួសថូ ឬផើងដាំដំណាំ ដែលការ៉ុងមានតម្លៃថោក និងងាយស្រួលរក។ លើសពីនេះទៀត ផ្កា និងដំណាំផ្សេងៗដែលបានដាំនៅតាមសួនច្បារតូចៗនេះជួយបង្កើនភាពបៃតងក្នុងផ្ទះ និងបង្កើនអុកស៊ីសែនដែលមនុស្សត្រូវការចាំបាច់បំផុត។

# ៦. លទ្ធផលស្រាវជ្រាវសំខាន់ៗ

## ៦.១ ទម្រង់ដោះស្រាយសំណងមានលក្ខណៈខុសៗគ្នា

*តារាងទី២៖ សង្ខេបទម្រង់ដោះស្រាយសំណង*

| ល.រ | ឈ្មោះទីតាំងចាស់នៃលំនៅឋានក្រីក្រ | សំណង | ចំនួនខ្នងផ្ទះ | ចម្ងាយពីទីតាំងចាស់មកទីតាំងថ្មី | អាសយដ្ឋានទីតាំងថ្មី |
|---|---|---|---|---|---|
| ១ | បន្ទាយស្លឹក | ដីទំហំ ៤x១៥ម៉ែត្រ<br>ថវិកា១០០ដុល្លា<br>មិនមានផ្ទះ | ៨៧ | ៤៥ គីឡូម៉ែត្រ | ស្រុកខ្សាច់កណ្ដាល |
| ២ | បឹងតាមោក (ទីតាំងទី១) | ដីទំហំ ៥x១៨ម៉ែត្រ<br>ថវិកា១ ០០០ដុល្លារ<br>មិនមានផ្ទះ | ១១ | ១៦ គីឡូម៉ែត្រ | ខណ្ឌព្រែកព្នៅ |
| ៣ | បឹងតាមោក (ទីតាំងទី២) | លើកទី១ (១គ្រួសារ)<br>- ដីទំហំ ៥x៣០ម៉ែត្រ<br>- ថវិកា ១០ ០០០ដុល្លារ<br>- មិនមានផ្ទះ<br>លើកទី២ (១២គ្រួសារ)<br>- ដី១ប្លង់<br>- ដីទំហំ ៥x៣០ម៉ែត្រ<br>- ថវិកា១៥ ០០០ដុល្លារ<br>- ផ្ទះ១ខ្នង | ១៣ | ៩,៩ គីឡូម៉ែត | ខណ្ឌព្រែកព្នៅ |
| ៤ | ផ្លូវរថភ្លើង | ដីទំហំ ៤x១៥ម៉ែត្រ<br>មិនមានថវិកា<br>មិនមានផ្ទះ | ៣២ | ២,៤ គីឡូម៉ែត្រ | ខណ្ឌឫស្សីកែវ |
| ៥ | ទួលសង្កែ អេ | ដីទំហំ ៤x១៥ម៉ែត្រ<br>មិនមានថវិកា<br>មិនមានផ្ទះ | ៣០០ | ២,៨ គីឡូម៉ែត្រ | ខណ្ឌឫស្សីកែវ |
| ៦ | ចំរើនអភិវឌ្ឍ (ព្រែកប្រា) | ដីទំហំ ៤x១៥ម៉ែត្រ<br>មិនមានថវិកា<br>មិនមានផ្ទះ | ៣០០ | ៥,៩ គីឡូម៉ែត្រ | ខណ្ឌច្បារអំពៅ |

តារាងទី២ បង្ហាញពីព័ត៌មានសង្ខេបទាក់ទងនឹងទម្រង់ដោះស្រាយសំណងសម្រាប់ទីតាំងលំនៅឋានក្រីក្រទាំងប្រាំមួយ។ សំណងដែលបានពួកគេទទួលបានរួមមាន ដីឡូតិ៍ ថវិកា និងលំនៅឋាន ប៉ុន្តែសំណងទាំងនោះមិនស្មើរ។ ជាក់ស្ដែងទំហំដីដែលពួកគេទទួលបានមានតូចបំផុត ៤x១៥ ម៉ែត្រ និងធំបំផុត ៥x៣០ ម៉ែត្រ។ ចំណែក ថវិកាដែលទទួលបានមានលក្ខណៈខុសគ្នាខ្លាំងគឺច្រើនបំផុត ១០ ០០០ ដុល្លារ និងគ្រួសារមួយចំនួនទៀតមិនទទួលបានថវិកាសោះ។ លើសពីនេះទៀត បើពិនិត្យមើលទៅលើគម្លាតចម្ងាយពីទីតាំងចាស់ និងទីតាំងថ្មី ឃើញថាយន្តការនៃការផ្លាស់ទីតាំងលំនៅឋានក្រីក្រទាំងប្រាំមួយបានបង្ហាញពីភាពមិនស្មើគ្នានោះទេ។ ទីតាំងដែលនៅជិតបំផុតមានចម្ងាយ ២,៤គីឡូម៉ែត្រ និងទីតាំងដែលនៅឆ្ងាយបំផុតមានចម្ងាយរហូតដល់ ៤៥គីឡូម៉ែត្រ។ ទីតាំងដែលនៅឆ្ងាយជាងគេនោះ គឺពិបាកក្នុងការទទួលបានសេវាសាធារណៈគ្រប់គ្រាន់ បើធៀបទៅនឹងទីតាំងផ្សេងៗទៀត។




*ផែនទី១៖ ផែនទីបង្ហាញពីទីតាំងចាស់នៃលំនៅឋានក្រីក្រ និងទីតាំងលំនៅឋានថ្មី*

## ៦.២ ការទទួលបានសេវាសាធារណៈមិនពេញលេញ

តាមរយៈលទ្ធផលស្រាវជ្រាវរកឃើញថា កង្វះសេវាសារធាណៈសំខាន់ៗនៅទីតាំងថ្មីនាំឱ្យមានបញ្ហាប្រឈមជាច្រើន។ គ្រួសារមួយចំនួនមិនអាចទទួលបាននូវការគាំទ្រផ្នែកថវិកា និងសេវាសាធារណៈពេញលេញនៅឡើយទេ ដោយសារពួកគេបានចំណាយថវិកាផ្ទាល់ខ្លួន ឬថវិកាដែលបានមកពីកម្ចីផ្សេងៗ ដើម្បីសាងសង់លំនៅឋាននៅទីតាំងថ្មី។ មិនត្រឹមតែប៉ុណ្ណោះពួកគេក៏បានចំណាយថវិកាបន្ថែមទៀតសម្រាប់ថ្លៃសេវាតភ្ជាប់ប្រព័ន្ធទឹកស្អាត និងអគ្គិសនីជាដើម។ ចំណែកប័ណ្ណសមធម៌ដែលជាផ្នែកមួយជួយគាំពារដល់ជីវភាពរស់នៅរបស់ពួកគេ ក៏មិនអាចប្រើប្រាស់បន្តទៀតបានដែរ។ ការណ៍នេះបង្ហាញថា សេវាសាធារណៈមូលដ្ឋានសំខាន់ៗក៏ពួកគេមិនទទួលបានគ្រប់គ្រាន់ ឬពេញលេញដែរ ខណៈដែលរាជរដ្ឋាភិបាលបានបង្កើតគោលនយោបាយ និងកម្មវិធីអភិវឌ្ឍវិស័យសេវាសាធារណៈនានាជាច្រើន។ ក្នុងករណីសហគមន៍បន្ទាយស្លឹកដែលបានផ្លាស់ទីលំនៅទៅស្រុកខ្សាច់កណ្ដាលនៅខេត្តកណ្ដាលក្នុងឆ្នាំ២០២០ បាននឹងកំពុងប្រឈមបញ្ហាជីវភាពដោយសារ នៅពេលដែល

ពួកគេមកតាំងទីលំនៅថ្មីដំបូង មិនមានទឹកស្អាត ប្រព័ន្ធអគ្គិសនីប្រើប្រាស់ឡើយ ហើយពួកគេត្រូវចំណាយថវិកាផ្ទាល់ខ្លួនបន្ថែមទៀតពីសំណង ជាថវិកាដែលទទួលបានចំនួន ១០០ដុល្លារ និងសម្ភារៈដែលបានរុះរើពីទីតាំងចាស់ ដើម្បីសាងសង់លំនៅឋានថ្មី។

## ៦.៣ ឱកាសការងារ និងជីវភាព

លក្ខខណ្ឌឱកាសការងារនៅទីតាំងថ្មីមិនសមស្របទៅនឹងមុខរបរ ឬជំនាញដែលពួកគេធ្លាប់មាន។ កត្តានេះជាឧបសគ្គចម្បងដែលប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃ។ អ្នកដែលបានផ្លាស់ទីលំនៅទៅទីតាំងថ្មីភាគច្រើនត្រូវសម្រេចចិត្តផ្លាស់ប្តូរការងារ និងចំណាកស្រុកស្វែងរកការងារដើម្បីបានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ ដោយសារមិនមានការងារប្រហាក់ប្រហែលទៅនឹងជំនាញដែលពួកគេធ្លាប់ធ្វើពីមុន។ ជាក់ស្តែង ក្នុងចំណោម១១ គ្រួសារដែលបានផ្លាស់ទីលំនៅពីបឹងតាមោកទៅភូមិទួលពន្សាំង ក្នុងឆ្នាំ២០២១ មាន៨គ្រួសារហើយដែលបានចំណាកស្រុកទៅបណ្តាខេត្តផ្សេងទៀត ដើម្បីស្វែងរកឱកាសការងារ ហើយបច្ចុប្បន្ន គ្រួសារផ្សេងទៀតកំពុងរស់នៅក្នុងស្ថានភាពមិនទាន់សមរម្យ និងល្អប្រសើរនៅឡើយ។ ការងារដែលពួកគេអាចរកចំណូលសម្រាប់ជីវភាពគ្រួសារភាគច្រើនជាការងារសំណង់ ហើយមិនមានស្ថិរភាពប្រាក់ចំណូលដែលអាចធានាដល់ការទ្រទ្រង់ជីវភាពប្រចាំថ្ងៃបានឡើយ ដែលនេះមានន័យថា ពួកគេមិនមានការងារជាប់លាប់ប្រចាំខែឡើយ។ លើសពីនេះទៀតពួកគេប្រឈមនឹងការកេងប្រវ័ញ្ច និងការបោកប្រាស់ពីមេការសំណង់ផងដែរ។

## ៦.៤ ការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ

បញ្ហាបម្រែបម្រួលអាកាសធាតុ ជាពិសេសការកើនឡើងនៃកម្តៅ រួមផ្សំនឹងកង្វះខាតនៃការផ្តល់សំណងសមរម្យដូចជាលំនៅឋានដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅរបស់ប្រជាពលរដ្ឋដែលត្រូវបានផ្លាស់ទីលំនៅទៅកាន់ទីតាំងថ្មី។ លទ្ធផលពីការសម្ភាសរកឃើញថា ទម្រង់នៃការផ្តល់សំណងមិនមានភាពច្បាស់លាស់នៅឡើយ។ ក្នុងចំណោមប្រជាពលរដ្ឋសរុបប្រហែល ៧៩៦គ្រួសារនៃទីតាំងលំនៅឋានក្រីក្រទាំងប្រាំមួយ ដែលបានផ្លាស់ប្តូរទីតាំងលំនៅឋានថ្មីមិនទទួលបានសំណងជាលំនៅឋានឡើយ មានតែ១២គ្រួសារដែលបានផ្លាស់ទីលំនៅទៅភូមិស្រែដូនតូចក្នុងខណ្ឌព្រែកព្នៅប៉ុណ្ណោះទទួលបានសំណងជាផ្ទះថ្ម ដំបូលស័ង្កសី លើដីទំហំ ៥x៣០ម៉ែត្រ។ ទោះជាយ៉ាងណាក៏ដោយ ក៏លំនៅឋានដែលបានផ្តល់ជូនទាំងនោះមិនមានភាពធន់ និងអាចបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុបានឡើយ ដែលតម្រូវឱ្យពួកគេចំណាយថវិកាបន្ថែមដើម្បីសាងសង់លំនៅឋានដែលមានភាពល្អប្រសើរថែមទៀត។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋភាគច្រើនដែលបានផ្លាស់ទីលំនៅទៅទីតាំងថ្មីមិនទទួលបានសំណងជាលំនៅឋានឡើយ។ ការណ៍នេះ នាំឱ្យពួកគេជំពាក់បំណុលបន្ថែមដើម្បីសាងសង់លំនៅឋាន ហើយនៅតែមិនអាចសាងសង់លំនៅឋានដែលអាចទប់ទល់ទៅនឹងបម្រែបម្រួលអាកាសធាតុបានឡើយ។

## ៦.៥ បញ្ហាប្រឈមចម្បងៗនៃទីតាំងលំនៅឋានថ្មី

ចាប់តាំងពីការផ្លាស់ទីតាំងលំនៅឋានថ្មី ចន្លោះឆ្នាំ២០២០ មកដល់បច្ចុប្បន្ន ភាគច្រើននៅតែជួបប្រទះបញ្ហាប្រឈមចម្បងៗដូចជា កង្វះឱកាសការងារ បំណុល កង្វះលទ្ធភាពទទួលបានការសិក្សារបស់ក្មេងៗ មិនទទួលបានសេវាគាំពារសង្គមគ្រប់គ្រាន់ និងការបន្សាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសការកើនឡើងកម្តៅ។ មុខរបរជាកត្តាសំខាន់បំផុតដែលអាចឱ្យពួកគេទទួលបានប្រាក់ចំណូលសម្រាប់បំពេញតម្រូវការផ្សេងៗប្រចាំថ្ងៃ ប៉ុន្តែកង្វះយន្តការត្រឹមត្រូវដែលគិតគូរដល់ឱកាសការងាររបស់ពួកគេ គឺជាចំណុចសំខាន់មួយដែលគួរត្រូវបានគិតគូរពិចារណាឱ្យបានម៉ត់ចត់បំផុត។ បញ្ហាកង្វះឱកាសការងារនេះមិនត្រឹមតែប៉ះពាល់ដល់ប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យពួកគេមានវិបត្តិបំណុល មិនមានលទ្ធភាពផ្គត់ផ្គង់ការសិក្សារបស់កូនៗ ដែលកត្តាធ្វើឱ្យកុមារមួយចំនួនបោះបង់ការសិក្សា។ បញ្ហាប្រឈមទាំងនេះមានភាពប្រទាក់ក្រឡាគ្នា និងអាចប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេក្នុងរយៈពេលវែង។ ស្របគ្នាទៅនឹងបញ្ហាប្រាក់ ចំណូល កង្វះសេវាគាំពារសង្គមដូចជា ជំនួយសង្គម និងសន្តិសុខសង្គម រួមទាំងបញ្ហាកង្វះសេវាសុខាភិបាលក្នុងមូលដ្ឋានដែលមានប្រសិទ្ធភាព គឺជាកត្តាចម្បងមួយដែលអាចនាំឱ្យជីវភាពរបស់ពួកគេកាន់តែធ្លាក់ចុះ ព្រោះពួកគេត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាច្រើនសម្រាប់ព្យាបាលជម្ងឺម្តងៗ។



*រូបភាពទី៤៖ ស្ថានភាពមុខរបររបស់ប្រជាពលរដ្ឋនៅភូមិទួលពន្សាំង ឆ្នាំ២០២៥*

## ករណីសិក្សា៖ ស្ថានភាពជីវភាពក្រោយការផ្លាស់ទីតាំងលំនៅថ្មី

អ្នកស្រី សុភី (ឈ្មោះតំណាង) ធ្លាប់ជាសមាជិកសហគមន៍ម្នាក់នៅទីក្រុងភ្នំពេញ ដែលបានផ្លាស់ទីលំនៅទៅទីតាំងថ្មីដែលមានចម្ងាយឆ្ងាយប្រហែល៤៥ គីឡូម៉ែត្រ នៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលក្នុងឆ្នាំ២០២០ ដោយសារគម្រោងអភិវឌ្ឍន៍។ ចាប់តាំងពីការចាកចេញពីទីលំនៅដែលធ្លាប់រស់នៅជាយូរមកហើយ អ្នកស្រី និងស្វាមី រួមទាំងម្តាយចំណាស់ម្នាក់ តស៊ូរស់នៅក្នុងលំនៅឋានទ្រុឌទ្រោមមួយដែលបានសាងសង់ពីឈើ ស័ង្កសី និងសម្ភារៈផ្សេងទៀតដែលនៅសេសសល់ពីលំនៅឋានចាស់ដែលបានរុះរើដោយអារម្មណ៍ភ័យខ្លាចព្រោះតែគម្រោងអភិវឌ្ឍន៍។ ម្តាយចំណាស់របស់អ្នកស្រីបានរៀបរាប់ថា "*ពេលមកដល់ដំបូងកំសត់ណាស់ អត់មានទឹកភ្លើងទេ ទៅយកពីខាងណោះ (ខាងលិចទីតាំង) ជាង២គីឡូ (ម៉ែត្រ)*"។ ការចំណាយថវិកាជាច្រើនដើម្បីសាងសង់លំនៅឋាន និងការរស់នៅប្រចាំថ្ងៃ រួមទាំងធ្លាក់ចុះប្រាក់ចំណូលជាកត្តារុញច្រានភាពសុខដុមរមនាក្នុងគ្រួសារកាន់តែលំបាក ដោយស្វាមីអ្នកស្រីត្រូវចាកឆ្ងាយពីគ្រួសារទៅធ្វើការសំណង់នៅខេត្តផ្សេងទៀតដើម្បីបានប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ ជាច្រើនខែបន្ទាប់មកទៀត គ្រួសារអ្នកស្រីបន្តតស៊ូរស់នៅទាំងលំបាកថែមទាំងប្រឈមនឹងបញ្ហាជាច្រើនជាពិសេសការទទួលសេវាសុខាភិបាល និងអសន្តិសុខដូចជា ចោរលួចយកសម្ភារៈផ្សេងៗក្នុងផ្ទះ ដោយសារតែជញ្ជាំងស័ង្កសីដែលមានសភាពពុកផុយ ហើយក្នុងគ្រួសារមានតែមនុស្សស្រី អ្នកស្រីក៏បានលើកឡើងដែរថា "*វាអាងតែយើងអត់មានអ្នកនៅហើយជញ្ជាំងហ្នឹងមានជាប់អី*" ។ បញ្ហាបន្តបន្ទាប់ក៏បានកើតឡើងចំពោះគ្រួសារអ្នកស្រីគឺនៅពាក់កណ្តាលឆ្នាំ២០២៤ ម្តាយចំណាស់របស់គាត់បានជួបគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលឱ្យបាក់ជើង។ ទន្ទឹមនឹងនេះប័ណ្ណសមធម៌ក៏លែងប្រើប្រាស់បាន អ្នកស្រីមិនមានលទ្ធភាពព្យាបាលម្តាយនៅមន្ទីរពេទ្យទេ ព្រោះត្រូវចំណាយច្រើនខ្លាំង។ ជាជម្រើសចុងក្រោយអ្នកម្តាយចំណាស់របស់គាត់បានត្រឹមព្យាបាលជាមួយគ្រូខ្មែរ[២០] តាមរបៀបបុរាណព្រោះត្រូវចំណាយថវិកាតិចតួច។ មកដល់បច្ចុប្បន្ននេះជីវភាព គ្រួសារអ្នកស្រី នៅមិនទាន់ធូរធារនៅឡើយទេព្រោះកង្វះការទទួលបានសេវាសាធារណៈពេញលេញ។



*រូបភាពទី៥៖ ស្ថានភាពជីវភាព និងលំនៅឋានរបស់អ្នកស្រី សុភី (ឈ្មោះតំណាង) ឆ្នាំ ២០២៤*



*រូបភាពទី៦៖ជញ្ជាំងផ្នែកខាងក្រោយដែលត្រូវបានចោរគាស់ ឆ្នាំ២០២៤*

២០. គ្រូខ្មែរ ជាគ្រាមភាសាក្នុងតំបន់ដែលអ្នកស្រុកធ្លាប់ហៅ ឬម្យ៉ាងទៀតអាចហៅបានថា ជាគ្រូខ្មែរបុរាណ ដែលចេះចាំវិធីសាស្ត្រព្យាបាលជំងឺ ឬតឆ្អឹងតៗគ្នាតាមរបៀបបុរាណ។

# ៧.ការវិភាគការរកឃើញសំខាន់ៗធៀបនឹងទិដ្ឋភាពច្បាប់ សិទ្ធិមនុស្ស និងបម្រែបម្រួលអាកាសធាតុ

*ហេតុអ្វីរាជរដ្ឋាភិបាលកម្ពុជាផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងបទបញ្ញត្តិអន្តរជាតិ?*

ច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងបទបញ្ញត្តិអន្តរជាតិពាក់ព័ន្ធផ្សេងទៀតដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើន កិច្ចសហប្រតិបត្តិការ និងការរក្សាសណ្តាប់ធ្នាប់ពិភពលោក។ សារៈសំខាន់នៃច្បាប់អន្តរជាតិ និងបទបញ្ញត្តិទាំងនោះរួមមាន ធានាសន្តិភាព និងស្ថិរភាព[២១] ជួយសម្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច ធ្វើឱ្យបទបញ្ញត្តិនានាមានលក្ខណៈរួមគ្នា ជាពិសេសលើកកម្ពស់សិទ្ធិមនុស្ស[២២] និងការពារបរិស្ថាន។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ កំណត់កាតព្វកិច្ចដែលរដ្ឋត្រូវគោរព។ តាមរយៈការផ្តល់សច្ចាប័ន និងក្លាយជាភាគីនៃសន្ធិសញ្ញាអន្តរជាតិ រដ្ឋទាំងឡាយត្រូវមានកាតព្វកិច្ច និងករណីកិច្ចចំពោះសិទ្ធិមនុស្សក្រោមច្បាប់អន្តរជាតិដើម្បី គោរព ការពារ និងបំពេញ[២៣]។ ដូចនេះ ក្នុងករណីប្រទេសកម្ពុជាដែលជាសមាជិកនៃអង្គការសហប្រជាជាតិត្រូវគោរព ការពារ និងធានានូវសិទ្ធិរស់រានមានជីវិត ក៏ដូចជាសិទ្ធិទទួលបានលំនៅឋានសមរម្យឱ្យបានពេញលេញសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយគ្មានការរើសអើង ជាពិសេសទីតាំងលំនៅឋានក្រីក្រនៅទីក្រុងដែលជាក្រុមងាយរងគ្រោះ។

*តើយន្តការក្នុងការផ្លាស់ទីតាំងលំនៅឋានក្រីក្រទាំងប្រាំមួយ បានអនុវត្តពេញលេញស្របទៅនឹងច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិជាតិ និងអន្តរជាតិដែរឬទេ?*

ផ្អែកលើឯកសារពាក់ព័ន្ធ និងលទ្ធផលស្រាវជ្រាវ បង្ហាញឱ្យឃើញថាទីតាំងលំនៅឋានថ្មីទាំងប្រាំមួយមិនទាន់ទទួលបានលំនៅឋានសមរម្យដែលអាចឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុបានឡើយ។

ប្រសិនបើពិនិត្យមើលលើលក្ខណៈវិនិច្ឆ័យជាអប្បបរមាលើលំនៅឋានសមរម្យទាំង៧ចំណុចនៃកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិ (UN-Habitat) យើងអាចវិភាគលើចំណុចនីមួយៗដូចតទៅ៖

- *សុវត្ថិភាពក្នុងការកាន់កាប់៖* គិតចាប់តាំងពីឆ្នាំ២០២០ ដល់បច្ចុប្បន្ន ទីតាំងលំនៅឋានថ្មីទាំងប្រាំមួយមិនទាន់ទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិដីធ្លីប្រភេទប្លង់រឹង) ដែលបញ្ជាក់ការកាន់កាប់ដីធ្លីស្របច្បាប់នៅឡើយទេ ដោយបញ្ហានេះអាចទាក់ទងទៅនឹងគោលការណ៍នៃសម្បទានដី ឬដោយសារហេតុផលផ្សេងទៀត។ ការណ៍នេះ មានន័យថាពួកគេរស់នៅដោយមិនទាន់

២១. អង្គការសហប្រជាជាតិ អគ្គលេខាធិការអង្គការសហប្រជាជាតិ សន្ធិសញ្ញាឆ្នាំ២០១១ តាមរយៈ៖https://shorturl.at/Q2KNR
២២. អង្គការសហប្រជាជាតិ សន្ធិសញ្ញាឆ្នាំ២០១០ ឆ្ពោះទៅរកការចូលរួម និងការអនុវត្តជាសកល តាមរយៈ៖ https://treaties.un.org/doc/source/events/2010/Press_kit/fact_sheet_5_english.pdf
២៣. អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មូលដ្ឋាននៃច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ តាមរយៈ៖ https://www.un.org/en/about-us/udhr/foundation-of-international-human-rights-law

មានសុវត្ថិភាពនៅឡើយ ព្រោះមានតែវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុទេដែលអាចបញ្ជាក់ថាពួកគេមានសិទ្ធិពេញលេញក្នុងការចាត់ចែងប្រើប្រាស់ និងអាស្រ័យផលលើដីដែលពួកគេកំពុងរស់នៅ។ ជាក់ស្តែង គ្រួសារមួយចំនួនដែលផ្លាស់ទីលំនៅទៅភូមិវិហារសួគ៌តាំងពីឆ្នាំ២០២០ មិនទាន់មានសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីនៅឡើយទេ ដោយគ្រួសារដែលរស់នៅលើដីឡូត៍ចាប់ពីលេខ១ដល់៣២ មិនទាន់បានបំបែកក្បាលដីពីក្រុមហ៊ុននៅឡើយ ហើយពួកគេកំពុងតវ៉ារកដំណោះស្រាយជាបន្តបន្ទាប់រហូតដល់ថ្នាក់ខេត្ត។

- *ភាពអាចទទួលបានសេវាកម្ម សម្ភារៈ អគារ ឬកន្លែងផ្តល់សេវា និងហេដ្ឋារចនាសម្ព័ន្ធ៖* ក្នុងចំណោមទីតាំងលំនៅឋានក្រីក្រទាំងប្រាំមួយដែលបានផ្លាស់ទីលំនៅឋានថ្មី មានតែ២ទីតាំងទេដែលនៅជិតទីតាំងចាស់ជាងគេ គឺផ្លូវរថភ្លើង និងទួលសង្កែអេ ដែលមានចម្ងាយប្រហែល ២គីឡូម៉ែត្រពីទីតាំងចាស់។ ក្រៅពីនេះ ពួកគេបានផ្លាស់ទីតាំងលំនៅឋានថ្មីឆ្ងាយពីទីតាំងចាស់ដែលមានចម្ងាយចន្លោះពី៥គីឡូម៉ែត្រ ដល់៤៥ គីឡូម៉ែត្រដែលភាគច្រើនស្ថិតនៅឆ្ងាយពីទីក្រុង។ ដូចនេះ ពួកគេមិនមានលទ្ធភាពទទួលបាន សេវាកម្មហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈផ្សេងៗដែលមានលក្ខណៈប្រសើរដូចអ្នកនៅទីក្រុងឡើយ។ ឧទាហរណ៍ ១៣គ្រួសារដែលបានផ្លាស់ទីលំនៅពីបឹងតាមោក (ទីតាំងទី២) ទៅភូមិស្រែដូនតូចក្នុងឆ្នាំ២០២២ មកដល់បច្ចុប្បន្ននៅមិនទាន់ទទួលបានទឹកស្អាតប្រើប្រាស់នៅឡើយទេ រួមទាំងបញ្ហាផ្លូវលំក្នុងមូលដ្ឋានមានសភាពទ្រុឌទ្រោម និងបង្កការលំបាកក្នុងការធ្វើដំណើររបស់ពួកគេ។
- *ភាពអាចលៃលកបាន៖* ដោយសារតែសំណងផ្តល់ជូនប្រជាពលរដ្ឋដែលផ្លាស់ទីតាំងលំនៅឋានថ្មីភាគច្រើនមិនមានជាលំនៅឋានទេ ដូច្នេះពួកគេត្រូវចំណាយថវិកាផ្ទាល់ខ្លួន ឬថវិកាដែលបានមកពីកម្ចីផ្សេងៗ ដើម្បីសាងសង់ផ្ទះដោយខ្លួនឯង ដែលចំណុចនេះនាំឱ្យមានបញ្ហាប្រឈមផ្សេងៗសម្រាប់ពួកគេជាពិសេសពាក់ព័ន្ធនឹងហិរញ្ញវត្ថុគ្រួសារ។
- *ភាពអាចរស់នៅបាន៖* ដូចដែលបានបង្ហាញខាងលើ ភាគច្រើនសំណងដែលប្រជាពលរដ្ឋនៅទីតាំងលំនៅឋានថ្មីទាំងប្រាំមួយទទួលបាន មិនមានជម្រើសសំណងជាលំនៅឋានទេ មានតែ ១២គ្រួសារនៅភូមិស្រែដូនតូចប៉ុណ្ណោះទទួលបានសំណងជាលំនៅឋាន។ ម្យ៉ាងវិញទៀត ក្នុងចំណោមទីតាំងលំនៅឋានក្រីក្រទាំង៦ មានតែ២ប៉ុណ្ណោះ ដែលទទួលបានសំណងជាថវិកា ចំនួនច្រើនជាងគេ ១០ ០០០ ដុល្លារ។ ក្រៅពីនោះ ពួកគេត្រូវចំណាយថវិកាផ្ទាល់ខ្លួនដើម្បីសាងសង់លំនៅឋានដែលអាចរស់នៅបាន។ បញ្ហាដែលពួកគេភាគច្រើនមិនទទួលបានសំណងជាថវិកា និងលំនៅឋានបែបនេះ ជាឧបសគ្គចម្បងសម្រាប់ពួកគេក្នុងការទទួលបានលំនៅឋានសមរម្យ។ ការណ៍នេះមានន័យថាពួកគេត្រូវយកឈើ និងសម្ភារៈចាស់ៗដែលបានរុះរើមកធ្វើផ្ទះឡើងវិញនៅទីតាំងថ្មី និងប្រជាពលរដ្ឋដទៃទៀតត្រូវរកប្រាក់កម្ចីបន្ថែមដើម្បីសាងសង់ផ្ទះតាមលទ្ធភាពរបស់ពួកគេ។ ដូច្នេះ ពួកគេមិនមានលទ្ធភាពទទួលបានលំនៅឋានសមរម្យដែលមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុឡើយ។
- *ភាពអាចប្រើប្រាស់បាន៖* តាមរយៈលទ្ធផលស្រាវជ្រាវបានរកឃើញថា ប្រភេទលំនៅឋានដែលពួកគេកំពុងរស់នៅបច្ចុប្បន្នមានដូចជា

ប្រភេទទី១៖ ផ្ទះជញ្ជាំងឈើ និងដំបូលស័ង្កសី ប្រភេទទី២៖ ផ្ទះជញ្ជាំងស័ង្កសី និងដំបូលស័ង្កសី ប្រភេទទី៣៖ ផ្ទះជញ្ជាំងថ្ម និងដំបូលស័ង្កសី និងប្រភេទទី៤៖ ផ្ទះជញ្ជាំងថ្ម និងដំបូលក្បឿង។ បើប្រៀបធៀបរវាងផ្ទះទាំង៤ប្រភេទនេះ មានតែផ្ទះប្រភេទទី៤ទេ ដែលមានសមត្ថភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងមានភាពធន់។ ការវិភាគទៅលើស្ថានភាពលំនៅឋានរបស់ពួកគេអាចបង្ហាញថា មានតែទីតាំងលំនៅឋានថ្មីចំនួន២ប៉ុណ្ណោះ ដែលផ្លាស់ទីតាំងពីសហគមន៍ផ្លូវរថភ្លើង និងទួលសង្កែអេ មានលំនៅឋានប្រភេទទី៤។ ក្រៅពីនោះលំនៅឋានរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅទីតាំងថ្មីទាំង៤ផ្សេងទៀតមិនមានសមត្ថភាពធន់ទៅនឹងអាកាសធាតុត្រជាក់ សើម កម្ដៅ ភ្លៀង ខ្យល់ ការគំរាមកំហែងដទៃទៀតដល់សុខភាពបានឡើយ។

- *ទីតាំង៖* ទីតាំងលំនៅឋានក្រីក្រចំនួន៣ ក្នុងចំណោម៦ ដែលបានផ្លាស់ទីតាំងលំនៅឋានថ្មីឆ្ងាយជាងគេបំផុតគឺ នៅភូមិស្រែដូនតូច ភូមិទួលពន្សាំង ក្នុងខណ្ឌព្រែកព្នៅ និងភូមិវិហារសួគ៌ ក្នុងស្រុកខ្សាច់កណ្ដាល។ កត្តាទីតាំងថ្មីដែលមានចម្ងាយឆ្ងាយពីទីតាំងចាស់បែបនេះ ជារឿយៗនាំឱ្យពួកគេបាត់បង់ឱកាសការងារ ហើយពួកគេត្រូវបង្ខំចិត្តជួលផ្ទះនៅទីក្រុងវិញ ឬចំណាកស្រុកទៅបណ្ដាខេត្តផ្សេងៗ។ ដូចច្នេះហើយ ទីតាំងលំនៅឋានថ្មីទាំងនោះមិនមានភាពសមស្របសម្រាប់ពួកគេឡើយ។

- *ភាពសមស្របផ្នែកវប្បធម៌ និងប្រពៃណី៖* បញ្ហាគួរឱ្យកត់សម្គាល់ទាក់ទងវប្បធម៌ និងប្រពៃណីនេះគឺប្រឈមខ្លាំងពាក់ព័ន្ធនឹងទម្លាប់នៃការប្រកបមុខរបរ ជាពិសេសប្រជាពលរដ្ឋនៅភូមិស្រែដូនតូច និងភូមិទួលពន្សាំងដែលធ្លាប់តែជាអ្នកនេសាទនៅលើផ្ទៃបឹងតាមោក ដើម្បីបានប្រាក់ចំណូលប្រចាំថ្ងៃ បែរទៅរស់នៅតំបន់ភ្នំទៅវិញ។ ដូចនេះការរស់នៅកន្លែងថ្មីនេះ មិនសមស្របទៅនឹងទម្លាប់នៃការរស់នៅរបស់ពួកគេដូចពីមុនឡើយ។



*រូបភាពទី៧៖ សំណង់ជាផ្ទះនៅភូមិស្រែដូនតូច (ផ្ទះនៅខាងឆ្វេងត្រូវបានចំណាយថវិកាផ្ទាល់ខ្លួនបន្ថែមដើម្បីសាងសង់) ឆ្នាំ២០២៥*

# ៨. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា ការអនុវត្តយន្តការបណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅមិនទាន់ពេញលេញនៅឡើយ។ បញ្ហានេះទាមទារឱ្យរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធរួមគ្នាដោះស្រាយចំណុចខ្វះខាតដែលបានរកឃើញ។ ជាទូទៅ ការអភិវឌ្ឍត្រូវបានចាត់ទុកថា ជាការកែលម្អជារីវិជ្ជមាន ហើយប្រជាពលរដ្ឋ ជាពិសេសទីតាំងលំនៅឋានក្រីក្រដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍នានា គួរតែត្រូវបានពិចារណាក្នុងការផ្តល់ជម្រើសអភិវឌ្ឍន៍នៅនឹងកន្លែង ឬការផ្លាស់ ទីតាំងលំនៅឋានថ្មីដែលផ្តល់ជូនសំណង និងគិតគូរអំពីសិទ្ធិទទួលបានលំនៅឋានសមរម្យ។ ទោះជាយ៉ាងណាក៏ដោយ ទីតាំងលំនៅឋានក្រីក្រដែលបានផ្លាស់ទីតាំងលំនៅឋានថ្មី ជាពិសេសនៅភូមិស្រែដូនតូច ភូមិទួលពន្សាំង និងភូមិវិហារសួគ៌ជើង មិនទាន់ទទួលបានសេវាសាធារណៈពេញលេញ និងមិនទទួលបានលំនៅឋានសមរម្យស្របតាមលក្ខណៈវិនិច្ឆ័យជាអប្បបរមាលើលំនៅឋានសមរម្យនៃកម្មវិធីអង្គការសហប្រជាជាតិសម្រាប់លំនៅឋានមនុស្សជាតិនោះទេ។ កង្វះយន្តការផ្តល់សំណងសមរម្យ ជាកត្តានាំឱ្យប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការអភិវឌ្ឍមិនមានជីវភាពល្អប្រសើរ និងជាឧបសគ្គចំពោះរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ ជាងនេះទៅទៀត ភាគច្រើននៃលំនៅឋានរបស់ពួកគេមិនមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុឡើយ ខណៈដែលកម្ពុជាជាប្រទេសមួយដែលងាយរងគ្រោះពីបម្រែបម្រួលអាកាសធាតុ។ សរុបមក ការអភិវឌ្ឍក្នុងតំបន់ទាំងនេះ មិនបានធ្វើឱ្យជីវភាព ឬលក្ខខណ្ឌរស់នៅមានភាពប្រសើរឡើង នោះទេ ដោយគ្រួសារខ្លះប្រឈមមុខនឹងការធ្លាក់ចុះនៃប្រាក់ចំណូល និងកង្វះឱកាសការងារ ដែលបញ្ហានេះនាំឱ្យមានបំណុល និងបញ្ហាប្រឈមផ្សេងៗទៀត។

ការសិក្សានេះបង្ហាញពីបញ្ហាប្រឈមសំខាន់ៗ និងបញ្ហាបម្រែបម្រួលអាកាសធាតុចំពោះទីតាំងលំនៅឋានក្រីក្រដែលបានផ្លាស់ទីតាំងទៅតំបន់ឆ្ងាយ ដោយសារគម្រោងអភិវឌ្ឍន៍។ ទោះបីជាមានយន្តការសម្រាប់ ការបណ្តេញចេញ និងការតាំងទីលំនៅឋានថ្មីក៏ដោយ ក៏នៅតែមានភាពខ្វះចន្លោះក្នុងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងលំនៅឋានសមរម្យដែលជាតម្រូវការជាមូលដ្ឋានក្នុងការរស់នៅប្រចាំថ្ងៃសម្រាប់គ្រួសារដែលតាំងទីលំនៅថ្មីជាច្រើន។ ភាពខ្វះចន្លោះនៃការអនុវត្តគោលនយោបាយ អាចជាបញ្ហាប្រឈមក្នុងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋដែលជាក្រុមងាយរងគ្រោះ និងមិនអាចសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ ការរកឃើញសំខាន់ៗបង្ហាញថា លទ្ធភាពទទួលបានទឹកស្អាត អគ្គិសនី និងសេវាសាធារណៈសំខាន់ៗសម្រាប់ទីតាំងលំនៅឋានថ្មីនៅមានកម្រិតទាប សំណងមិនទាន់សមរម្យដែលមិនមានការកំណត់ច្បាស់លាស់ និងលំនៅឋានមិនទាន់ស្របតាមស្តង់ដារអន្តរជាតិ។ ស្ថានភាពនេះធ្វើឱ្យភាពក្រីក្រ និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុកាន់តែធ្ងន់ធ្ងរ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះប្រកបដោយប្រសិទ្ធភាព ការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងនិរន្តរភាព កម្ពុជាត្រូវតែដោះស្រាយបញ្ហាទាំងនេះជាបន្ទាន់ ដោយអ្នកបង្កើតគោលនយោបាយ និងអ្នកពាក់ព័ន្ធគួរពង្រឹងការអនុវត្តយន្តការផ្តល់សំណងសមរម្យ ផ្តល់អាទិភាពដល់សេវាសាធារណៈ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ហើយមានភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុ។




រូបភាពទី៨៖ ស្ថានភាពផ្ទះនៅភូមិចំពុះក្អែកដែលសាងសង់ដោយសម្ភារៈពីទីតាំងចាស់ ឆ្នាំ២០២៤

# ៩. អនុសាសន៍

តាមរយៈលទ្ធផលស្រាវជ្រាវដែលបានរកឃើញពីបញ្ហាប្រឈមសំខាន់ៗរបស់ប្រជាពលរដ្ឋបន្ទាប់ពីការបណ្តេញចេញ និងតាំងទីលំនៅថ្មី និងភាពខ្វះចន្លោះក្នុងការអនុវត្តយន្តការផ្តល់សំណងសមរម្យ អនុសាសន៍មួយចំនួនត្រូវបានស្នើរឡើងសម្រាប់ភាគីពាក់ព័ន្ធរួមមាន រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល គិតគូរពិចារណាក្នុងការដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន។

១) ធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន

- ❑ រាជរដ្ឋាភិបាល៖ បង្កើតក្រុមការងារពិសេសនៅមូលដ្ឋានដោះស្រាយបញ្ហាផ្លាស់ទីតាំងនៅលំហានថ្មី ដើម្បីធានាថាការផ្គត់ផ្គង់ទឹកស្អាត អនាម័យ អគ្គិសនី ការថែទាំសុខភាព ការអប់រំ និងប្រព័ន្ធគាំពារសង្គមគ្រប់គ្រាន់។
- ❑ ដៃគូអភិវឌ្ឍន៍៖ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ផ្លាស់ទីតាំងលំនៅឋានថ្មី។

២) បង្កើនភាពធន់នឹងបម្រែបម្រួលអាកាសធាតុ

- ❑ រាជរដ្ឋាភិបាល៖ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ ដូចជាលំនៅឋានដែលមានទីតាំងនៅតំបន់មិនមានទឹកលិច និងប្រើប្រាស់គ្រឿងបរិក្ខារសម្រាប់សាងសង់លំនៅឋានដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ ម្យ៉ាងទៀត ការរៀបចំផែនការរយៈពេលវែងសម្រាប់ការផ្លាស់ទីតាំងលំនៅឋានថ្មីចំពោះប្រជាពលរដ្ឋដែលរស់នៅតំបន់មិនរៀបរយគួរតែត្រូវបានធ្វើឡើង ដើម្បីកំណត់បាននូវទីតាំងថ្មីច្បាស់លាស់ មានសេវាសាធារណៈ និងមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ដែលមានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ។
- ❑ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖
  - ■ បង្កើតក្របខ័ណ្ឌគោលនយោបាយដែលគិតគូរអំពីទីធ្លាបៃតងដែលមានលក្ខណៈស្តង់ដាររួម សម្រាប់ការរៀបចំផែនការអភិវឌ្ឍក្រុង ជាពិសេសការរៀបចំទីតាំងលំនៅឋានថ្មី សម្រាប់ទីតាំងលំនៅឋានក្រីក្រ ឬតំបន់មិនរៀបរយក្នុងទីក្រុង។
  - ■ លើកទឹកចិត្តក្នុងការរៀបចំផែនការដីធ្លីសម្រាប់លំនៅឋាន និងសំណង់អគារ ដែលអាចសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ហើយការសាងសង់គួរមានតម្លៃសមរម្យសម្រាប់គ្រួសារដែលមានចំណូលទាប ជាពិសេសគ្រួសារដែលផ្លាស់ទីលំនៅឋានថ្មី។
- ❑ អង្គការសង្គមស៊ីវិល៖ រៀបចំកម្មវិធីបណ្តុះបណ្តាលប្រជាពលរដ្ឋនៅទីតាំងលំនៅឋានថ្មី អំពី យុទ្ធសាស្ត្របន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។
- ❑ ប្រជាពលរដ្ឋនៅទីតាំងលំនៅឋានថ្មី៖ រៀបចំសម្អាតអនាម័យនៅតាមផ្ទះជាប្រចាំ និងដាំដើមឈើបន្ថែមដើម្បីបង្កើនភាពបៃតង និងជាម្លប់ទប់ទល់នឹងកម្តៅ។

៣) លើកកម្ពស់ជីវភាពរស់នៅ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអាជ្ញាធរមូលដ្ឋាន សហការជាមួយវិស័យឯកជន ដើម្បីបង្កើតមជ្ឈមណ្ឌលការងារ និងកម្មវិធីអភិវឌ្ឍជំនាញនៅជិតទីតាំងលំនៅឋានថ្មី។ ពួកគេក៏អាចផ្តល់ការឧបត្ថម្ភធនធាន ឬកញ្ចប់ជំនួយលើកទឹកចិត្តដល់អាជីវកម្មក្នុងការវិនិយោគលើការបង្កើតការងារសម្រាប់ប្រជាពលរដ្ឋនៅក្នុងតំបន់នោះ។

៤) ពង្រឹងការអនុវត្តគោលនយោបាយ

- រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានគួរតែបង្កើតក្របខ័ណ្ឌសម្របសម្រួលដើម្បីត្រួតពិនិត្យប្រព័ន្ធវាយតម្លៃផលប៉ះពាល់រយៈពេលវែង និងស្វែងរកការគាំទ្រជាថវិកាពីដៃគូអភិវឌ្ឍន៍ ដើម្បីធានាថាគោលនយោបាយទាំងនោះអនុវត្តទទួលបានប្រសិទ្ធភាព និងតម្លាភាព។
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពង្រឹងការតាមដាន និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រគោលនយោបាយឱ្យបានពេញលេញ ជាពិសេសគោលនយោបាយជាតិ ស្តីពីលំនៅឋាន ឆ្នាំ២០១៤។
- អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ គួរចុះត្រួតពិនិត្យ សម្ភាស និងវាយតម្លៃឡើងវិញនូវលទ្ធភាពក្នុងការទទួលបានប័ណ្ណសមធម៌សម្រាប់ប្រជាពលរដ្ឋនៅទីតាំងថ្មី។
- ដៃគូអភិវឌ្ឍន៍៖ គាំទ្រប្រព័ន្ធត្រួតពិនិត្យដើម្បីវាយតម្លៃផលប៉ះពាល់រយៈពេលវែងនៃគោលនយោបាយផ្លាស់ទីលំនៅលើសុខុមាលភាពប្រជាពលរដ្ឋ។

៥) ជំរុញបរិយាបន្នសង្គម

- រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល៖ រៀបចំសកម្មភាពកសាងបណ្តាញ និងពង្រឹងទំនាក់ទំនងសង្គមសម្រាប់ប្រជាពលរដ្ឋនៅទីតាំងថ្មីឡើងវិញ។
- ដៃគូអភិវឌ្ឍន៍៖ បង្កើតកម្មវិធីមូលនិធិដើម្បីផ្តល់ការគាំទ្រផ្នែកសង្គម និងសុខភាពផ្លូវចិត្តសម្រាប់គ្រួសារដែលផ្លាស់ទីលំនៅថ្មី។

៦) ដោះស្រាយបញ្ហាប្រឈមរួម

- រាជរដ្ឋាភិបាល៖ ធានាថាដំណើរការផ្លាស់ទីលំនៅត្រូវបានធ្វើឡើងដោយតម្លាភាព ដោយមានការយល់ព្រមដែលមិនមានភាពភ័យខ្លាច ឬបង្ខិតបង្ខំ និងមានការចូលរួមពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់។ ទោះបីជាយ៉ាងណា ប្រសិនបើអាចអភិវឌ្ឍនៅនឹងកន្លែងបាន រាជរដ្ឋាភិបាលគួរតែរៀបចំជាលំនៅឋាន សម្រាប់ប្រជាជន និងលក់ឬជួលឱ្យប្រជាជនក្នុងតម្លៃមួយទាប និងរយៈពេលវែង ព្រមទាំងមានច្រើនជម្រើសទាំងលំនៅឋានសម្រាប់អាជីវកម្ម និងលំនៅឋានសម្រាប់រស់នៅ។ រដ្ឋាភិបាលអាចធ្វើការជាមួយសង្គមស៊ីវិលក្នុងការស្រង់ទិន្នន័យ និងធ្វើការជាមួយក្រុមហ៊ុនឯកជនក្នុងការសាងសង់ និងគ្រប់គ្រងកិច្ចសន្យាលក់ទិញជាមួយប្រជាពលរដ្ឋ។
- អង្គការសង្គមស៊ីវិល៖ សហការ និងតាមដានការអនុវត្តគោលនយោបាយនានាពាក់ព័ន្ធនឹងការបណ្តេញចេញ និងផ្លាស់ទីលំនៅ ដែលធានាឱ្យបាននូវភាពសមស្របតាមស្តង់ដារអន្តរជាតិ។

សរុបមក ការសិក្សានេះបង្ហាញពីតម្រូវការបន្ទាន់សម្រាប់វិធីសាស្ត្ររួម និងបរិយាបន្នដើម្បីដោះស្រាយបញ្ហាប្រឈមដែលទាក់ទងនឹងការផ្តល់សេវាសាធារណៈ និងភាពធន់នឹងបម្រែបម្រួលអាកាសធាតុនៅក្នុងទីតាំងផ្លាស់ទីលំនៅថ្មីក្នុងប្រទេសកម្ពុជា។ កិច្ចសហការប្រកបដោយប្រសិទ្ធភាពក្នុងចំណោមភាគីពាក់ព័ន្ធ ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងការពង្រឹងគោលនយោបាយ គឺមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។



(+855) 023 431 555

sttcambodia

https://teangtnaut.org/